ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រុមប្រឹក្សាជាតិគណនេយ្យ

# CIFRS 4

# កិច្ចសន្យាធានារ៉ាប់រង

## Insurance Contracts

ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ

International Accounting Standards Board (IASB®)

# អារម្ភកថា

ដោយសារនយោបាយ “**ឈ្នះ-ឈ្នះ**” របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ប្រទេសកម្ពុជាសម្រេចបាននូវឯកភាពជាតិ, បូរណភាពទឹកដី, អធិបតេយ្យ, និងសុខសន្តិភាពពេញលេញទូទាំងប្រទេស ហើយបង្កើតបានជាបុរេលក្ខណៈសម្បត្តិសម្រាប់ពង្រឹងស្ថិរភាពនយោបាយ, សណ្តាប់ធ្នាប់សង្គម និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលបានលើកកម្ពស់ជីវភាព, សុខមាលភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជាបន្តបន្ទាប់។ ដើម្បីបន្ត និងពង្រឹងនូវវឌ្ឍនភាពនេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញនិងធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់នូវផែនការ និងយុទ្ធសាស្ត្រមួយនានា ដូចជា “**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី១, ទី២ និង ទី៣**”, “**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**”, “**យុទ្ធសាស្ត្រត្រីកោណ**”, “**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០**” និង “**យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨**” ព្រមទាំងធ្វើការកែទម្រង់លើគ្រប់វិស័យ ដែលក្នុងនោះ ការកែទម្រង់លើការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុ និងប្រព័ន្ធគណនេយ្យ ទាំងក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជន ជាអទិភាពចម្បងមួយ។

**ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ** ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ និងក្រុមប្រឹក្សាជាតិគណនេយ្យ ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ០៣ ខែ មីនា ឆ្នាំ ២០០៣ ជាក្របខ័ណ្ឌគតិយុត្ត និងក្របខ័ណ្ឌស្ថាប័ន ក្នុងទិសដៅអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ការកែទម្រង់គណនេយ្យនិងសវនកម្មឯកជន ដើម្បីបង្កើតនូវបរិយាកាសទីផ្សារប្រកួតប្រជែងប្រកបដោយតម្លាភាព សម្រាប់ជំរុញកំណើនធុរៈកិច្ច និងវិនិយោគឆ្លងប្រទេសនៅកម្ពុជា ។ ក្រុមប្រឹក្សាជាតិគណនេយ្យ (ក.ជ.គ) ដែលជាស្ថាប័នបញ្ញត្តិករ និងនិយ័តករនៅក្នុងវិស័យគណនេយ្យនិងសវនកម្ម មានភារកិច្ចចម្បងក្នុងការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យ, ស្តង់ដាសវនកម្ម និងក្របខ័ណ្ឌទស្សនទានគណនេយ្យតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចកម្ពុជា ដោយអនុលោមតាមស្តង់ដាអន្តរជាតិ និងការវិវឌ្ឍជាអន្តរជាតិនៅក្នុងវិស័យនេះ ។

សៀវភៅស្តីពី “**ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា** ” ត្រូវបានបកប្រែទាំងស្រុងចេញពីស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standard Board-IASB) ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការប្រើប្រាស់របស់សហគ្រាសអាជីវកម្មក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុរបស់ខ្លួន សំដៅធានាបាននូវតម្លាភាព, គណនេយ្យភាព និងភាពអាចជឿទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាកាតព្វកិច្ចរបស់ម្ចាស់សហគ្រាស, គណនេយ្យករ

និងសវនករផងដែរ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា មិនត្រឹមតែរួម-ចំណែកលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូលពន្ធជូនរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ព័ត៌មានហិរញ្ញវត្ថុដ៏មានសារៈប្រយោជន៍ដល់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនៅក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនានា ។

ការដាក់ឱ្យអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រ និងជាផែនការនៃការកសាងហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ ក្នុងផ្នែកអភិបាលកិច្ចសាជីវកម្ម និងហេដ្ឋារចនាសម្ព័ន្ធនៃ "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**" របស់រាជរដ្ឋា-ភិបាលកម្ពុជា ដែលបានទទួលការអនុម័តពីគណៈរដ្ឋមន្ត្រីនៅក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។

ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខ្ញុំសូមវាយតម្លៃខ្ពស់ និង សម្តែងនូវការកោតសរសើរដ៏ស្មោះចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម **ងី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ និងសមាជិកក្រុមប្រឹក្សាជាតិគណនេយ្យទាំងអស់ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃលេខាធិការដ្ឋាន ក.ជ.គ ដែលបានខិតខំពុះពារគ្រប់ឧបសគ្គ និងលះបង់ពេលវេលា, ធនធាន និងកំលាំងកាយចិត្ត ក្នុងការធ្វើឱ្យឯកសារដ៏មានតម្លៃនេះលេចចេញជារូបរាងឡើង។

*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន**

# **អារម្ភកថា**

៙

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា បានរំលេចនូវទិសដៅចម្បង៤ គឺកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ព្រមទាំងបានបង្ហាញយ៉ាងច្បាស់នូវគោលបំណងចម្បងរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចបាននិងការរក្សានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រួមទាំងកិច្ចអភិវឌ្ឍន៍សង្គមកិច្ចមួយដ៏រឹងមាំនិងជានិរន្តន៍ ដែលធានាកម្រិតជីវភាពនិងសុខដុមភាពរបស់ប្រជាជនឱ្យប្រសើរឡើងជាលំដាប់។ នៅក្នុងបរិការណ៍នេះ វិស័យគណនេយ្យនិងសវនកម្មមានតួនាទីយ៉ាងសំខាន់នៅក្នុងជីវិតសេដ្ឋកិច្ចនិងសង្គម ពិសេសនៅក្នុងការធានាភាពត្រឹមត្រូវច្បាស់លាស់, តម្លាភាព, គណនេយ្យភាព និងអភិបាលកិច្ចល្អ ក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជន។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលបាន ចាត់ទុកវិស័យគណនេយ្យនិងសវនកម្មនេះ ជាផ្នែកមួយដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់ជាតិ ដូចមានចែងនៅក្នុង “**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០**”។

អនុវត្តតាមស្មារតីនៃយុទ្ធសាស្ត្រខាងលើ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ បានជំរុញការអភិវឌ្ឍន៍វិស័យនេះយ៉ាងសកម្ម ផ្តើមចេញពីការកសាងមូលដ្ឋានគ្រឹះសម្រាប់ការចុះកិច្ចបញ្ជិកាគណនេយ្យនិងការធ្វើសវនកម្ម តាមរយៈការរៀបចំនិងដាក់ឱ្យប្រើនូវច្បាប់ស្តីពី “គណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ” នៅឆ្នាំ២០០២។ ផ្អែកតាមស្មារតីនៃច្បាប់ខាងលើ ក្នុងខែមករា ឆ្នាំ២០០៩ ស្តង់ដារគណនេយ្យកម្ពុជា ដែលរួមមាន“ *ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា* ” និង “*ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម*” ត្រូវបានដាក់ឱ្យប្រើដោយប្រកាស*លេខ ០៦៨ ស.ហ.វ-ប្រ.ក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥*។ ក្នុងន័យនេះ សហគ្រាសសាធារណៈនិងក្រុមហ៊ុនឯកជននានាដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅកម្ពុជា ត្រូវប្រើស្តង់ដាគណនេយ្យកម្ពុជាដើម្បីធ្វើជាមូលដ្ឋានសារវន្តនិងជាក្របខ័ណ្ឌសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងភាពអាចជឿទុកចិត្តបានលើរបាយការណ៍ហិរញ្ញវត្ថុពីសំណាក់អ្នកប្រើប្រាស់និងសាធារណៈជន ហើយក៏អាចជាបច្ច័យមួយជួយជំរុញកំណើនចំណូលសារពើពន្ធ និងជួយគាំទ្រដល់វឌ្ឍភាពនិងស្ថេរភាពនៃទីផ្សារហិរញ្ញវត្ថុ ក៏ដូចជាជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ។

អាស្រ័យហេតុនេះ ខ្ញុំសូមលើកទឹកចិត្តសហគ្រាសដែលមានការពាក់ពន្ធ័ ឱ្យអនុវត្តស្តង់ដាដែលមាននៅក្នុងសៀវភៅនេះដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងសម្រាប់ការគ្រប់គ្រងផ្ទៃក្នុងនិងសម្រាប់ការដាក់បង្ហាញទៅអ្នកដែលមានការពាក់ព័ន្ធនានា។

*រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋលេខាធិការ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា**

**ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ**

**ឱ តាយី**

ក. និយមន័យពាក្យបច្ចេកទេស

ខ. និយមន័យកិច្ចសន្យាធានារ៉ាប់រង

គ. វិសោធនកម្មចំពោះ ស.រ.ហ.អ ដទៃទៀត

ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិលេខ ៤ ស្តីពី *កិច្ចសន្យាធានារ៉ាប់រង* (ស.រ.ហ.អ ៤) ត្រូវបានចែកចេញជាកថាខណ្ឌពី ១-៤៥ និងជាឧបសម្ព័ន្ធ ក-គ។ គ្រប់កថាខណ្ឌទាំងអស់មានអំណាចស្មើគ្នា។ កថាខណ្ឌជា **ប្រភេទដិត** លើកឡើងអំពីគោលការណ៍ចម្បង។ វាក្យស័ព្ទដែលបានកំណត់នៅក្នុងឧបសម្ព័ន្ធ ក ជា *អក្សរផ្តេក* ជាពាក្យដែលទើបតែកើតមានលើកទី១នៅក្នុងស្តង់ដា។

និយមន័យរបស់ពាក្យបច្ចេកទេស ត្រូវបានផ្តល់នៅក្នុងសទ្ទានុក្រម នៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ។ ស.រ.ហ.អ លេខ ៤ អាចត្រូវបានអាននៅក្នុងបរិបថនៃគោលដៅរបស់វា និងមូលដ្ឋាននៃការសន្និដ្ឋាន *អារម្ភកថានៃស្តង់ដាររបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ* និង *ក្របខ័ណ្ឌស្តង់ដារាយការណ៍ហិរញ្ញវត្ថុ*។ ស្តង់ដាគណនេយ្យអន្តរជាតិលេខ ៨ ស្តីពី *គោលនយោបាយគណនេយ្យ ការប្រែប្រួលនៃការប៉ាន់ស្មានគណនេយ្យ និងកំហុសឆ្គង* ផ្តល់នូវមូលដ្ឋានមួយសម្រាប់ជ្រើសរើសនិងអនុវត្តគោលនយោបាយគណនេយ្យ នៅពេលដែលគ្មានគោលការណ៍ណែនាំជាក់លាក់។

## ហេតុផលនៃការចេញ ស.រ.ហ.អ

សផ១ នេះជា ស.រ.ហ.អ ទី១ ដែលនិយាយអំពី កិច្ចសន្យាធានារ៉ាប់រង។ ការអនុវត្តគណនេយ្យសម្រាប់កិច្ចសន្យាធានារ៉ាប់រងមានផ្សេងៗគ្នា និងតែងតែខុសពីការអនុវត្តនៅក្នុងវិស័យដទៃទៀត។ ដោយសារតែអង្គភាពភាគច្រើននឹងអនុម័ត ស.រ.ហ.អ ក្នុងឆ្នាំ ២០០៥ ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិបានចេញស្តង់ដានេះ÷

(ក) ដើម្បីធ្វើឱ្យប្រសើរឡើង ចំពោះការកត់ត្រាគណនេយ្យ សម្រាប់កិច្ចសន្យាធានារ៉ាប់រង រហូតទាល់តែក្រុមប្រឹក្សាបញ្ចប់នូវដំណាក់កាលទី២នៃគម្រោងរបស់ខ្លួនស្តីពីកិច្ចសន្យាធានារ៉ាប់រង។

(ខ) ដើម្បីតម្រូវឱ្យអង្គភាពណាក៏ដោយ ដែលចេញកិច្ចសន្យាធានារ៉ាប់រង (អ្នកធានារ៉ាប់រង) លាតត្រដាងព័ត៌មានអំពីកិច្ចសន្យាទាំងនោះ។

សផ២ ស.រ.ហ.អ នេះ គឺជាដំណាក់កាលសំខាន់មួយឈានទៅរកដំនាក់កាលទី២នៃគម្រោងនេះ។ ក្រុមប្រឹក្សាបានសន្យាថានឹងបញ្ចប់ដំណាក់កាលទី២នេះដោយគ្មានការពន្យាពេល នៅពេលដែលក្រុមប្រឹក្សាបានអង្កេត ទៅលើទស្សនទាន និងបញ្ហាកើតក្នុងពេលអនុវត្តពាក់ព័ន្ធ និងបានបំពេញទាំងស្រុងតាមនីតិវិធីពេញលេញរបស់ខ្លួន។

## ចរិកលក្ខណៈចម្បងនៃ ស.រ.ហ.អ នេះ

សផ៣ ស.រ..ហ.អ អនុវត្តចំពោះរាល់កិច្ចសន្យាធានារ៉ាប់រងទាំងអស់ (រាប់បញ្ចូលទាំងកិច្ចសន្យាធានារ៉ាប់រងបន្ត) ដែលអង្គភាពមួយចេញ និងចំពោះកិច្ច

សន្យាធានារ៉ាប់រងបន្តដែលអង្គភាពមាន លើកលែងតែកិច្ចសន្យាជាក់លាក់នានាដែលគ្របដណ្តប់ដោយ ស.រ.ហ.អ ដទៃទៀត។ វាមិនអនុវត្ត ចំពោះទ្រព្យសកម្ម និងបំណុលដទៃទៀត របស់អ្នកធានារ៉ាប់រងទេ ដូចជា ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ក្នុងក្របខ័ណ្ឌ នៃវិសាលភាពនៃ ស.រ.ហ.អ លេខ ៩ *ឧបករណ៍ហិរញ្ញវត្ថុ*។ ម្យ៉ាងវិញទៀត ស្តង់ដានេះមិនលើកឡើងអំពីការកត់ត្រាគណនេយ្យ ដោយអ្នកកាន់សិទ្ធិធានារ៉ាប់រងនោះទេ។

សផ៤ ស.រ.ហ.អ ផ្តល់ការលើកលែងជាបណ្តោះអាសន្ន (ដូចជា នៅក្នុងដំណាក់កាលទី ១ នៃគម្រោងនេះ)ពីការតម្រូវមួយចំនួននៃស្តង់ដារដទៃទៀត រួមបញ្ចូលទាំងការតម្រូវក្នុងការពិចារណាលើ *ក្របខ័ណ្ឌស្តង់ដា* ក្នុងការរើសយកគោលនយោបាយគណនេយ្យ សម្រាប់កិច្ចសន្យាធានារ៉ាប់រង។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ស.រ.ហ.អ ÷

(ក) ហាមឃាត់មិនឱ្យមានសំវិធានធនសម្រាប់ការទាមទារ ដែលអាចកើតមានតាមកិច្ចសន្យាដែលមិនកើតមានឡើងនាចុងកាលបរិច្ឆេទរាយការណ៍ (ដូចជា គ្រោះមហន្តរាយ និងសមភាពកម្មសំវិធានធន)។

(ខ) តម្រូវឱ្យសាកល្បងលើភាពគ្រប់គ្រាន់នៃបំណុលធានារ៉ាប់រងដែលបានទទួលស្គាល់ និងការសាកល្បងលើការថយចុះតម្លៃ សម្រាប់ទ្រព្យសកម្មធានារ៉ាប់រងបន្ត។

(គ) តម្រូវឱ្យអ្នកធានារ៉ាប់រងរក្សាទុក នូវបំណុលធានារ៉ាប់រង នៅក្នុងរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុ រហូតដល់បំណុលទាំងអស់នោះត្រូវបានបង់ ឬបដិសេធចោល ឬផុតកំណត់ និងតម្រូវឱ្យ

បង្ហាញ នូវបំណុលហិរញ្ញវត្ថុ ដោយពុំមានការទូទាត់ជាមួយនឹងទ្រព្យសកម្មធានារ៉ាប់រងបន្តទាក់ទិន។

សផ៥ ស.រ.ហ.អ អនុញ្ញាតឲ្យអ្នកធានារ៉ាប់រងផ្លាស់ប្តូរគោលនយោបាយគណនេយ្យរបស់ខ្លួនសម្រាប់កិច្ចសន្យាធានារ៉ាប់រង តែប្រសិនបើរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនបង្ហាញនូវព័ត៌មានកាន់តែមានភាពពាក់ព័ន្ធ និងកាន់តែមានការទុកចិត្តតិចឬច្រើន។ ជាពិសេស អ្នកធានារ៉ាប់រងមិនអាចប្រើនូវកិច្ចប្រតិបត្តិ ដូចខាងក្រោម ទោះបីជាអ្នកធានារ៉ាប់រងនោះ អាចបន្តប្រើគោលនយោបាយគណនេយ្យដែលទាក់ទិននឹងការប្រតិបត្តិទាំងនោះ÷

(ក) ដោយប្រើបំណុលហិរញ្ញវត្ថុតាមមូលដ្ឋានមិនអប្បហា

(ខ) ដោយប្រើសិទ្ធិតាមកិច្ចសន្យាចំពោះកម្រៃគ្រប់គ្រងវិនិយោគ នាពេលអនាគត ក្នុងចំនួនទឹកប្រាក់មួយលើសពីតម្លៃពិតគណនេយ្យរបស់វា ដូចដែលបានបញ្ជាក់ដោយការប្រៀបធៀបជាមួយតម្លៃជាក់ស្តែងដែលយកដោយអ្នកចូលរួមក្នុងទីផ្សារដទៃទៀតសម្រាប់សេវាស្រដៀងគ្នា។

(គ) ដោយប្រើ គោលនយោបាយគណនេយ្យ មិនឯកភាព សម្រាប់បំណុលធានារ៉ាប់រងរបស់អង្គភាពបុត្រសម្ព័ន្ធ។

សផ៦ ស.រ.ហ.អ អនុញ្ញាតឲ្យដាក់ចេញគោលនយោបាយគណនេយ្យមួយដែលទាក់ទិននឹងការវាស់វែង បំណុលធានារ៉ាប់រង ដែលបានកំណត់អនុលោមទៅនឹងការិយបរិច្ឆេទនីមួយៗ ដើម្បីបង្ហាញឲ្យឃើញនូវ អត្រាការប្រាក់ទីផ្សារបច្ចុប្បន្ន (និង បង្ហាញនូវការប៉ាន់ស្មាននិងការសន្មត់ដទៃទៀត ប្រសិនបើអ្នកធានារ៉ាប់រងសម្រេចរើសយកដូចនេះ)។ បើពុំមានការអនុញ្ញាត នោះ

ទេ អ្នកធានារ៉ាប់រងអាចត្រូវបានតម្រូវឲ្យអនុវត្តការផ្លាស់ប្ដូរគោលនយោបាយគណនេយ្យ ដោយស្របទៅនឹងបំណុលប្រហាក់ប្រហែលទាំងអស់។

សផ៧ អ្នកធានារ៉ាប់រង មិនចាំបាច់ផ្លាស់ប្ដូរ គោលនយោបាយគណនេយ្យរបស់ខ្លួនចំពោះកិច្ចសន្យាធានារ៉ាប់រងដើម្បីលុបចោលការប្រុងប្រយ័ត្នហួសហេតុ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើ អ្នកធានារ៉ាប់រងវាស់វែងរួចហើយនូវកិច្ចសន្យាធានារ៉ាប់រងជាមួយនឹងការប្រុងប្រយ័ត្នគ្រប់គ្រាន់ ហើយនោះ អ្នកធានារ៉ាប់រងមិនត្រូវដាក់ចេញការប្រុងប្រយ័ត្នបន្ថែមនោះទេ។

សផ៨ មានការសន្មត់ជាមុន ដែលមិនអាចជំទាស់បានមួយ ដែលរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកធានារ៉ាប់រង នឹងក្លាយទៅជាមានភាពជាប់ពាក់ព័ន្ធ និងការជឿទុកចិត្តតិចតួចប្រសិនបើអ្នកធានារ៉ាប់រងដាក់ចេញគោលនយោបាយគណនេយ្យដែលបង្ហាញនូវគម្លាតវិនិយោគ នាពេលអនាគត ក្នុងការវាស់វែងកិច្ចសន្យាធានារ៉ាប់រង។

សផ៩ នៅពេលដែលអ្នកធានារ៉ាប់រងផ្លាស់ប្ដូរគោលនយោបាយគណនេយ្យរបស់ខ្លួនចំពោះបំណុលធានារ៉ាប់រង អ្នកធានារ៉ាប់រងអាចចាត់ថ្នាក់ឡើងវិញនូវទ្រព្យសកម្មហិរញ្ញវត្ថុមួយចំនួន ឬទាំងអស់ ថា "តាមតម្លៃទីផ្សារតាមរយៈចំណេញ-ខាត"។

សផ១០ ស.រ.ហ.អ ៖

(ក) បញ្ជាក់ថា អ្នកធានារ៉ាប់រង មិនចាំបាច់គិតអំពីនិស្សន្ទបង្កប់ដាច់ដោយឡែកពីគ្នាតាមតម្លៃទីផ្សារនោះទេ ប្រសិនបើ និស្សន្ទបង្កប់បំពេញបានតាមអត្ថន័យនៃកិច្ចសន្យាធានារ៉ាប់រង។

(ខ) តម្រូវឲ្យអ្នកធានារ៉ាប់រងបំបែក (ដូចជា គិតដាច់ដោយឡែកពីគ្នា) សមាសធាតុប្រាក់តម្កល់នៃកិច្ចសន្យាធានារ៉ាប់រងមួយចំនួន ដើម្បី

ចៀសវាងការលុបចោលទ្រព្យសកម្ម និងបំណុលពីរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន។

(គ) បញ្ជាក់ភាព ដែលអាចអនុវត្តបាននៃការប្រតិបត្តិ ដែលជួនកាលត្រូវបានគេស្គាល់ថាជា “ គណនេយ្យជានាម ”។

(ឃ) អនុញ្ញាតឲ្យមានការបង្ហាញទូលំទូលាយនូវកិច្ចសន្យាធានារ៉ាប់រងដែលបានទិញ នៅក្នុងការរួមបញ្ចូលអាជីវកម្ម ឬក្នុងអនុប្បទានផលបត្រ។

(ង) លើកលែងអំពី ទិដ្ឋភាពមានដែនកំណត់ នៃលក្ខណៈពិសេសនៃការចូលរួមក្នុងការសម្រេចចិត្ត (ដោយឆន្ទានុសិទ្ធិ) ដែលមាននៅក្នុងកិច្ចសន្យាធានារ៉ាប់រង ឬក្នុងឧបករណ៍ហិរញ្ញវត្ថុ។

សផ១១ ស.រ.ហ.អតម្រូវឲ្យលាតត្រដាងព័ត៌មានដើម្បីជួយអ្នកប្រើប្រាស់ឲ្យយល់អំពីៈ

(ក) ចំនួនទឹកប្រាក់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកធានារ៉ាប់រងដែលកើតពីកិច្ចសន្យាធានារ៉ាប់រង។

(ខ) ចរិកលក្ខណៈនិងទំហំនៃហានិភ័យ ដែលកើតពីកិច្ចសន្យាធានារ៉ាប់រង។

សផ១២ (លុបចោល)

## ឥទ្ធិពលជាសក្កានុពលនៃសំណើនាពេលអនាគត

សផ១៣ (លុបចោល)

## គោលដៅ

១ គោលដៅនៃ ស.រ.ហ.អ នេះ គឺដើម្បីបញ្ជាក់អំពីការរាយការណ៍ហិរញ្ញវត្ថុសម្រាប់ *កិច្ចសន្យាធានារ៉ាប់រង* ដែលធ្វើដោយអង្គភាព (ដែលពិពណ៌នាក្នុងស្តង់ដានេះថាជា *អ្នកធានារ៉ាប់រង*) រហូតដល់ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិបំពេញចប់នូវដំណាក់កាលទី២នៃគម្រោងរបស់ខ្លួនស្តីពីកិច្ចសន្យាធានារ៉ាប់រង។ ជាពិសេស ស្តង់ដានេះ តម្រូវ÷

(ក) ឲ្យមានការធ្វើឲ្យប្រសើរឡើង ដោយមានព្រំដែន នៃការកត់ត្រាគណនេយ្យដោយអ្នកធានា ចំពោះកិច្ចសន្យាធានារ៉ាប់រង។

(ខ) ឲ្យមានការលាតត្រដាងព័ត៌មានដែលបញ្ជាក់និងពន្យល់អំពីចំនួនទឹកប្រាក់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកធានា ដែលកើតពីកិច្ចសន្យាធានារ៉ាប់រង និងជួយដល់អ្នកប្រើប្រាស់របាយការណ៍ទាំងនោះយល់ដឹងអំពីបរិមាណ ពេលវេលា និងភាពមិនប្រាកដប្រជានៃលំហូរសាច់ប្រាក់ពីកិច្ចសន្យាធានារ៉ាប់រង។

## វិសាលភាព

២ អង្គភាពមួយ ត្រូវអនុវត្ត ស.រ.ហ.អ នេះ ចំពោះ÷

(ក) កិច្ចសន្យាធានារ៉ាប់រង (រាប់បញ្ចូលទាំង*កិច្ចសន្យាធានារ៉ាប់រងបន្ត*) ដែលអង្គភាពបានចេញនិងកិច្ចសន្យាធានារ៉ាប់រងបន្តដែលអង្គភាពមាន។

(ខ) ឧបករណ៍ហិរញ្ញវត្ថុ ដែលអង្គភាពបានបោះផ្សាយ ដោយមាន *លក្ខណៈពិសេស នៃការចូលរួម ក្នុងការសម្រេចចិត្ត (ដោយ*

*ឆន្ទានុសិទ្ធិ)* (សូមមើលកថាខ័ណ្ឌ ៣៥)។ ស.រ.ហ.អ លេខ ៧ ស្តីពី *ឧបករណ៍ហិរញ្ញវត្ថុ: ការលាតត្រដាងព័ត៌មាន* បានតម្រូវឲ្យមានការលាតត្រដាងព័ត៌មានអំពីឧបករណ៍ហិរញ្ញវត្ថុ រួមទាំងឧបករណ៍ហិរញ្ញវត្ថុដែលមានលក្ខណៈពិសេសនេះ។

៣ ស.រ.ហ.អ នេះ មិនលើកឡើងអំពីទិដ្ឋភាពផ្សេងទៀត នៃការកត់ត្រាគណនេយ្យដែលធ្វើដោយអ្នកធានារ៉ាប់រង ដូចជា ការកត់ត្រាគណនេយ្យសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលកាន់កាប់ដោយអ្នកធានារ៉ាប់រង និងបំណុលហិរញ្ញវត្ថុដែលចេញផ្សាយដោយអ្នកធានារ៉ាប់រង នោះទេ (សូមមើលស្តង់ដាគណនេយ្យអន្តរជាតិលេខ ៣២ ស្តីពី*ឧបករណ៍ហិរញ្ញវត្ថុ: ការបង្ហាញ* ស្តង់ដាគណនេយ្យអន្តរជាតិលេខ ៣៩ ស្តីពី *ឧបករណ៍ហិរញ្ញវត្ថុ: ការទទួលស្គាល់និងការវាស់វែង* ស.រ.ហ.អ លេខ ៧ និង ស.រ.ហ.អ លេខ ៩ ស្តីពី*ឧបករណ៍ហិរញ្ញវត្ថុ*) លើកលែងតែអ្វីដែលមានចែងក្នុងវិធានអន្តរកាលនៅក្នុងកថាខ័ណ្ឌ ៤៥។

៤ អង្គភាពមួយមិនត្រូវអនុវត្តស្តង់ដានេះ ចំពោះ÷

(ក) ការធានាចំពោះផលិតផលដែលចេញដោយផ្ទាល់ដោយផលិតករ អ្នកលក់ដុំ ឬអ្នកលក់រាយ (សូមមើល ស្តង់ដាគណនេយ្យអន្តរជាតិលេខ ១៨ ស្តីពី*ចំណូល* និង ស្តង់ដាគណនេយ្យអន្តរជាតិលេខ ៣៧ ស្តីពី*សំវិធានធន បំណុលយថាហេតុ* និង *ទ្រព្យសកម្មយថាហេតុ*)។

(ខ) ទ្រព្យសកម្ម និងបំណុល របស់និយោជក ក្រោមផែនការអត្ថប្រយោជន៍បុគ្គលិក (សូមមើលស្តង់ដាគណនេយ្យអន្តរជាតិលេខ ១៩ ស្តីពី*អត្ថប្រយោជន៍បុគ្គលិក* និង ស.រ.ហ.អ លេខ ២

ស្តីពី*ការទូទាត់ផ្អែកលើចំណែកហ៊ុន*) និងកាតព្វកិច្ចអត្ថប្រយោជន៍ចូលនិវត្តន៍ ដែលរាយការណ៍ តាមរយៈផែនការអត្ថប្រយោជន៍សម្រាប់ការចូលនិវត្តន៍ ដែលបានកំណត់ (សូមមើល ស្តង់ដាគណនេយ្យអន្តរជាតិលេខ ២៦ ស្តីពី*ការកត់ត្រាគណនេយ្យ និងការរាយការណ៍ ដោយផែនការអត្ថប្រយោជន៍ សម្រាប់ការចូលនិវត្តន៍*)។

(គ) សិទ្ធិតាមកិច្ចសន្យា ឬកាតព្វកិច្ចតាមកិច្ចសន្យាដែលអាចយកទៅប្រើប្រាស់នាពលអនាគត ឬសិទ្ធិក្នុងការប្រើប្រាស់ដែលអាចមានជាយថាហេតុ លើធាតុមិនមែនហិរញ្ញវត្ថុ (ដូចជា ថ្លៃអាជ្ញាប័ណ្ណមួយចំនួន សួយសារ ការទូទាត់ចំពោះភតិសន្យាជាយថាហេតុ និងធាតុប្រហាក់ប្រហែល) ក៏ដូចជា ការធានាចំពោះតម្លៃ ដែលនៅសល់របស់ភតិកៈដែលបង្កប់នៅក្នុងភតិសន្យាហិរញ្ញវត្ថុ(សូមមើល ស្តង់ដាគណនេយ្យអន្តរជាតិលេខ ១៧ ស្តីពី*ភតិសន្យា* ស្តង់ដាគណនេយ្យអន្តរជាតិ លេខ ១៨ ស្តីពី *ចំណូល* និងស្តង់ដាគណនេយ្យអន្តរជាតិលេខ ៣៨ ស្តីពី*ទ្រព្យសកម្មអរូបិយ*)។

(ឃ) កិច្ចសន្យាធានារ៉ាប់រងហិរញ្ញវត្ថុ លើកលែងតែអ្នកចេញកិច្ចសន្យានោះបានអះអាងយ៉ាងច្បាស់ពីមុនមកថា គេចាត់ទុក កិច្ចសន្យាបែបនេះជាកិច្ចសន្យាធានារ៉ាប់រង ហើយបានប្រើនូវ កំណត់ត្រាគណនេយ្យ ដែលអាចអនុវត្តបានចំពោះកិច្ចសន្យាធានារ៉ាប់រង ដែលក្នុងករណីនេះ អ្នកចេញកិច្ចសន្យា អាចរើសយកមកអនុវត្តនូវទាំងស្តង់ដាគណនេយ្យអន្តរជាតិលេខ ៣២ ស.រ.ហ.អ លេខ ៧ និង ស.រ.ហ.អ លេខ ៩ និងទាំងស្តង់ដារនេះ ចំពោះ

កិច្ចសន្យាធានារ៉ាប់រងហិរញ្ញវត្ថុ។ អ្នកចេញកិច្ចសន្យា អាចធ្វើជំរើសយកតាមកិច្ចសន្យានីមួយៗ ប៉ុន្តែការរើសយកកិច្ចសន្យានីមួយៗមិនអាចដកហូតមកវិញបានទេ។

(ង) តម្លៃតបស្នងយថាហេតុ ដែលត្រូវបង់ ឬដែលត្រូវទទួលនៅក្នុងការរួមបញ្ចូលអាជីវកម្ម (សូមមើល ស.រ.ហ.អ លេខ ៣ ស្តីពី *ការរួមបញ្ចូលអាជីវកម្ម*)។

(ច) *កិច្ចសន្យាធានារ៉ាប់រងដោយផ្ទាល់* ដែលអង្គភាពបានធ្វើ (ដូចជាកិច្ចសន្យាធានារ៉ាប់រងដោយផ្ទាល់ដែលនៅក្នុងនោះ អង្គភាព គឺជា *អ្នកកាន់សិទ្ធិធានារ៉ាប់រង*។

៥ ដើម្បីឲ្យមានភាពងាយស្រួល ក្នុងការបង្ហាញនូវទឡ្ហីករណ៍ថាតើ អង្គភាពចេញកិច្ចសន្យាត្រូវបានចាត់ទុកឬមិនត្រូវបានចាត់ទុកថាជាអ្នកធានារ៉ាប់រង ដើម្បីបំពេញគោលបំណងច្បាប់ឬការគ្រប់គ្រង ស.រ.ហ.អ នេះ រៀបរាប់អំពីអង្គភាពណា ដែលចេញកិច្ចសន្យាធានារ៉ាប់រង ថាជាអ្នកធានារ៉ាប់រងមួយ។

៦ កិច្ចសន្យាធានារ៉ាប់រងបន្ត គឺជាប្រភេទមួយ នៃកិច្ចសន្យាធានារ៉ាប់រង។ ដូចនេះ រាល់ទឡ្ហីករណ៍ទាំងអស់សម្រាប់កិច្ចសន្យាធានារ៉ាប់រងដែលមានក្នុងស្តង់ដានេះ ក៏ត្រូវអនុវត្តចំពោះកិច្ចសន្យាធានារ៉ាប់រងបន្តផងដែរ។

## ឧបករណ៍និស្សន្ទបង្កប់

៧ ស.រ.ហ.អ តម្រូវឲ្យអង្គភាពមួយបែងចែកដាច់ពីគ្នានូវនិស្សន្ទបង្កប់មួយចំនួនពីកិច្ចសន្យា វាស់វែងនិស្សន្ទទាំងនោះ តាម*តម្លៃទីផ្សារ* ព្រមទាំងបញ្ចូលការប្រែប្រួលនានា លើតម្លៃទីផ្សាររបស់និស្សន្ទ នៅក្នុងចំណេញ-

ខាត។ ស.រ.ហ.អ លេខ ៩ អនុវត្តចំពោះនិស្សន្ទដែលបង្កប់នៅក្នុងកិច្ចសន្យាធានារ៉ាប់រង វាលែងតែនិស្សន្ទបង្កប់ គឺជាកិច្ចសន្យាធានារ៉ាប់រងខ្លួនឯង។

៨ ដូចដែលមានការលើកលែងមួយចំពោះការតម្រូវនៅក្នុង ស.រ.ហ.អ លេខ ៩ អ្នកធានារ៉ាប់រងមិនត្រូវបំបែកនិងវាស់វែងតម្លៃទីផ្សារ នូវ ជម្រើសរបស់អ្នកកាន់សិទ្ធិធានារ៉ាប់រង ដើម្បីបោះបង់ចោលនូវ កិច្ចសន្យាធានារ៉ាបរងសម្រាប់ចំនួនកំណត់មួយ (ឬ សម្រាប់ចំនួនមួយដែលផ្អែកលើមូលដ្ឋាននៃចំនួនកំណត់និងលើអត្រាការប្រាក់) ទោះបីជាថ្លៃលក់ខុសពីតម្លៃគណនេយ្យពិតរបស់*បំណុលធានារ៉ាប់រងក៏ដោយ។* ទោះបីជាយ៉ាងណាក៏ដោយ ក៏ការតម្រូវនៅក្នុង ស.រ.ហ.អ លេខ ៩ ត្រូវអនុវត្តចំពោះជម្រើសដាក់លក់វិញ ឬសិទ្ធិជម្រើសបោះបង់ចោលសាច់ប្រាក់ ដែលបង្កប់នៅក្នុងកិច្ចសន្យាធានារ៉ាប់រង ប្រសិនបើតម្លៃបោះបង់ចោល ប្រែប្រួលដោយឆ្លើយតបទៅនឹងការប្រែប្រួលលើអថេរហិរញ្ញវត្ថុ (ដូចជា មូលធន ឬ ថ្លៃទំនិញ ឬ សន្ទស្សន៍) ឬអថេរមិនមែនហិរញ្ញវត្ថុ ដែលមិនជាក់លាក់ ចំពោះភាគីនៃកិច្ចសន្យា។ម្យ៉ាងវិញទៀត ការតម្រូវទាំងនោះក៏អនុវត្តផងដែរ ប្រសិនបើលទ្ធភាពរបស់អ្នកកាន់កិច្ចសន្យាក្នុងការអនុវត្តជម្រើសដាក់លក់វិញ ឬសិទ្ធិជម្រើសបោះបង់ចោលសាច់ប្រាក់ ត្រូវបានបង្កើតឲ្យមាន ដោយការផ្លាស់ប្តូរអថេរនោះ (ឧទាហរណ៍ ជម្រើសដាក់លក់វិញ ដែលអាចត្រូវបានអនុវត្តប្រសិនបើសន្ទស្សន៍ទីផ្សារមូលបត្រ មកដល់កម្រិតមួយជាក់លាក់)។

៩ កថាខ័ណ្ឌ ៨ អនុវត្តដូចគ្នាដែរ ចំពោះជម្រើសក្នុងការបោះបង់ចោលឧបករណ៍ហិរញ្ញវត្ថុដែលមានលក្ខណៈពិសេសនៃការចូលរួមសម្រេចចិត្ត (ដោយឆន្ទានុសិទ្ធិ)។

## **ការមិនចងក្រងបញ្ចូលគ្នានៃធាតុប្រាក់តម្កល់**

១១ កិច្ចសន្យាធានារ៉ាប់រងមួយចំនួន មានទាំងសមាសធាតុធានារ៉ាប់រង និងទាំង *សមាសធាតុនៃប្រាក់តម្កល់*។ ក្នុងករណីខ្លះ អ្នកធានារ៉ាប់រង ត្រូវបានតម្រូវឬអនុញ្ញាតឱ្យមិនចងក្រងនូវសមាសធាតុ ទាំងនោះ÷

(ក) ការមិនចងក្រងត្រូវបានតម្រូវ ប្រសិនបើលក្ខខណ្ឌទាំងពីរខាងក្រោមត្រូវបានបំពេញ÷

១-អ្នកធានារ៉ាប់រងអាចវាស់វែងសមាសធាតុ នៃប្រាក់តម្កល់ (រួមបញ្ចូលទាំងសិទ្ធិបោះបង់ចោលដែលបង្កប់)ដាច់ដោយ ឡែក ពីគ្នា (មានន័យថា ដោយគ្មានការពិចារណាលើសមាសធាតុធានារ៉ាប់រង)។

២-គោលនយោបាយគណនេយ្យរបស់អ្នកធានារ៉ាប់រង មិនតម្រូវផ្សេងពីនេះ ឱ្យអ្នកធានារ៉ាប់រងទទួលស្គាល់នូវកាតព្វកិច្ច និងសិទ្ធិទាំងអស់ដែលកើតពីធាតុធានារ៉ាប់រង។

(ខ) ការបំបែកត្រូវបានអនុញ្ញាត ប៉ុន្តែមិនតម្រូវ ប្រសិនបើអ្នកធានារ៉ាប់រងអាចវាស់វែងសមាសធាតុ នៃប្រាក់តម្កល់ដាច់ដោយឡែកពីគ្នា ដូចមាននៅក្នុងចំណុច (ក)១ ប៉ុន្តែ គោលនយោបាយគណនេយ្យរបស់អ្នកធានារ៉ាប់រង តម្រូវឱ្យទទួលស្គាល់នូវកាតព្វ-កិច្ច និងសិទ្ធិទាំងអស់ ដែលកើតពីសមាសធាតុនៃប្រាក់តម្កល់ ដោយមិនគិតអំពីមូលដ្ឋាន ដែលបានប្រើប្រាស់ ដើម្បីវាស់វែងសិទ្ធិ និងកាតព្វកិច្ចទាំងនោះ។

(គ) ការបំបែកត្រូវបានហាមឃាត់ ប្រសិនបើ អ្នកធានារ៉ាប់រងមិនអាចវាស់វែងនូវសមាសធាតុនៃប្រាក់តម្កល់ដាច់ដោយឡែកពីគ្នាដូចមាននៅក្នុងចំណុច (ក)១។

១១ ខាងក្រោម គឺជាឧទាហរណ៍មួយនៃករណីពេលដែលគោលនយោបាយគណនេយ្យរបស់អ្នកធានារ៉ាប់រង មិនតម្រូវឲ្យគាត់ទទួលស្គាល់គ្រប់កាតព្វកិច្ចទាំងអស់ដែលកើតពីសមាសធាតុនៃប្រាក់តម្កល់។ អនុប្បទានិកម្នាក់ទទួលបាននូវសំណងទូទាត់សម្រាប់ការខាតបង់ពី *ការធានារ៉ាប់រងបន្ត* ប៉ុន្តែកិច្ចសន្យាបានបង្ខំឲ្យអនុប្បទានិកចំណាយ ឡើងវិញនូវសំណងនៅក្នុងឆ្នាំក្រោយនាពេលអនាគត។ កាតព្វកិច្ចនេះ កើតពីសមាសធាតុនៃប្រាក់តម្កល់។ ប្រសិនបើ គោលនយោបាយគណនេយ្យរបស់អនុប្បទានិកអាចអនុញ្ញាតឲ្យគាត់ទទួលស្គាល់ ការទូទាត់ថាជាចំណូលដោយគ្មានការទទួលស្គាល់កាតព្វកិច្ចដែលកើតមាន នោះការមិនចងបញ្ចូលគ្នា ត្រូវបានតម្រូវឲ្យធ្វើ។

១២ ដើម្បីចងភ្ជាប់កិច្ចសន្យា អ្នកធានារ៉ាប់រងត្រូវ÷

(ក) អនុវត្តស្តង់ដានេះ ចំពោះធាតុធានារ៉ាប់រង។

(ខ) អនុវត្ត ស.រ.ហ.អ លេខ ៩ ចំពោះសមាសធាតុនៃប្រាក់តម្កល់។

## ការទទួលស្គាល់និងការវាស់វែង

ការលើកលែងបណ្តោះអាសន្នពី ស.រ.ហ.អ ដទៃទៀត

១៣ កថាខ័ណ្ឌ ១០-១២ នៃស្តង់ដា គណនេយ្យអន្តរជាតិ លេខ ៨ ស្តីពី *គោលនយោបាយគណនេយ្យ ការប្រែប្រួលនៃការប៉ាន់ស្មានគណនេយ្យ និងកំហុសឆ្គង* កំណត់ច្បាស់អំពីលក្ខណៈវិនិច្ឆ័យ សម្រាប់អង្គភាពមួយប្រើប្រាស់ក្នុងការបង្កើតនូវគោលនយោបាយគណនេយ្យ ប្រសិនបើគ្មាន ស.រ.ហ.អ អនុវត្តជាពិសេសចំពោះធាតុមួយនោះទេ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏ស្តង់ដារនេះ លើកលែងមិនឲ្យអ្នកធានារ៉ាប់រងអនុវត្ត

នូវលក្ខណៈវិនិច្ឆ័យទាំងនោះ ចំពោះគោលនយោបាយ គណនេយ្យ របស់ខ្លួនចំពោះ÷

(ក) កិច្ចសន្យាធានារ៉ាប់រងដែលអ្នកធានារ៉ាប់រងចេញឱ្យ (រួមបញ្ចូលទាំងថ្លៃដើមទិញពាក់ព័ន្ធ និងទ្រព្យសកម្មអរូបិយពាក់ព័ន្ធ ដូចជាថ្លៃដើមនិងទ្រព្យសកម្មដែលបានពិពណ៌នានៅក្នុងកថាខ័ណ្ឌ ៣១ និង៣២ និង

(ខ) កិច្ចសន្យាធានារ៉ាប់រងបន្តដែលអ្នកធានារ៉ាប់រងមាន។

១៤ យ៉ាងណាក៏ដោយ ស.រ.ហ.អ នេះ មិនលើកលែងចំពោះអ្នកធានារ៉ាប់រងពីភាពជាប់ពាក់ព័ន្ធមួយចំនួននៃលក្ខណៈវិនិច្ឆ័យនៅក្នុងកថាខ័ណ្ឌ១០-១២ នៃស្តង់ដាគណនេយ្យអន្តរជាតិលេខ ៨ ។ ជាពិសេស អ្នកធានារ៉ាប់រង÷

(ក) មិនត្រូវទទួលស្គាល់ថាជា បំណុលនូវសំវិធានធនណាចំពោះការទាមទារនាពេលអនាគតដែលអាចកើតមានប្រសិនបើការទាមទារទាំងនោះកើតឡើងតាមកិច្ចសន្យាធានារ៉ាប់រង ដែលមិនមែនកើតមាន នាចុងការិយបរិច្ឆេទរាយការណ៍ (ដូចជា សំវិធានធនសម្រាប់វិនាសកម្ម និងសំវិធានធនសមភាពកម្មជាដើម)។

(ខ) ត្រូវអនុវត្ត *ការសាកល្បងភាពគ្រប់គ្រាន់នៃបំណុល* ដែលបានពិពណ៌នានៅក្នុងកថាខ័ណ្ឌ ១៥-១៩។

(គ) ត្រូវលុបចោលបំណុលធានារ៉ាប់រង (ឬផ្នែកមួយនៃធានារ៉ាប់រង) ពីរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុនៅពេល និងតែនៅពេលបំណុលបានរលត់ ដូចជា នៅពេលដែល កាតព្វកិច្ចដែលបាន

កំណត់នៅក្នុងកិច្ចសន្យាត្រូវបានលុបចោល ឬបដិសេធ ឬផុតពេលកំណត់។

(ឃ) មិនត្រូវទូទាត់÷

១-*ទ្រព្យសកម្មនៃការធានារ៉ាប់រងបន្ត* ជាមួយនឹងបំណុលពាក់ព័ន្ធការធានារ៉ាប់ពាក់ព័ន្ធ

២-ចំណូល ឬចំណាយពីកិច្ចសន្យាធានារ៉ាប់រងបន្ត ជាមួយនឹងចំណាយ ឬចំណូលពីកិច្ចសន្យាធានារ៉ាប់រងបន្ត។

(ង) ត្រូវពិចារណាថាតើ ទ្រពសម្បត្តិពីការធានារ៉ាប់រងបន្តត្រូវបានថយចុះតម្លៃដែរឬទេ (សូមមើលកថាខ័ណ្ឌ ២០)។

## ការសាកល្បងនាពគ្រប់គ្រាន់នៃបំណុល

១៥ អ្នកធានារ៉ាប់រង ត្រូវវាយតម្លៃនៅចុងការិយបរិច្ឆេទរាយការណ៍នីមួយៗ ថាតើបំណុលធានារ៉ាប់រងដែលបានទទួលស្គាល់របស់ខ្លួន មានភាពគ្រប់គ្រាន់ឬទេ ដោយប្រើការប៉ាន់ស្មានជាក់ស្តែងនៃលំហូរសាច់ប្រាក់នាពេលអនាគត តាមកិច្ចសន្យាធានារ៉ាប់រងរបស់ខ្លួន។ ប្រសិនបើការវាយតម្លៃនោះបង្ហាញថាតម្លៃពិតគណនេយ្យនៃបំណុលធានារ៉ាប់រងរបស់ខ្លួន (ដកចេញនូវថ្លៃដើមទិញពន្យាពាក់ព័ន្ធ និងទ្រព្យ សកម្មអរូបិយពាក់ព័ន្ធ ដូចជាអ្វីដែលបានពិពណ៌នានៅក្នុងកថាខ័ណ្ឌ ៣១ និង ៣២) មិនគ្រប់គ្រាន់ដោយគិតដល់លំហូរសាច់ប្រាក់ដែលបានប៉ាន់ស្មាននាពេលអនាគត កង្វះខាតទាំងអស់ត្រូវតែបានទទួលស្គាល់នៅក្នុងចំណេញ-ខាត។

១៦ ប្រសិនបើអ្នកធានារ៉ាប់រងអនុវត្តនូវការសាកល្បងភាពគ្រប់គ្រាន់នៃបំណុល ដែលជាការបំពេញនូវការតម្រូវអប្បបរិមាដែលបានកំណត់ ស.រ.ហ.អ នេះ មិនតម្រូវឱ្យមានលក្ខខណ្ឌតម្រូវបន្ថែមទៀតទេ ។ លក្ខខណ្ឌតម្រូវអប្បបរិមា មានដូចខាងក្រោម÷

(ក) ការសាកល្បងពិនិត្យ អំពីការប៉ាន់ស្មានជាក់ស្តែង នៃលំហូរសាច់ប្រាក់តាមកិច្ចសន្យាទាំងអស់ និង នៃលំហូរសាច់ប្រាក់ពាក់ព័ន្ធ ដូចជា ថ្លៃដើមដោះស្រាយពាក្យបណ្តឹង ក៏ដូចជាលំហូរសាច់ប្រាក់បានមកពីជម្រើសនិងការធានាបង្កប់។

(ខ) ប្រសិនបើ ការសាកល្បងបង្ហាញថា បំណុលមិនគ្រប់គ្រាន់នោះ កង្វះខាតទាំងអស់ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ-ខាត។

១៧ ប្រសិនបើ គោលនយោបាយរបស់អ្នកធានារ៉ាប់រង មិនតម្រូវឱ្យមានការធ្វើការសាកល្បងភាពគ្រប់គ្រាន់ នៃបំណុល ដែលនាំឱ្យបំពេញបានតាមលក្ខខណ្ឌតម្រូវអប្បបរិមាមានក្នុងកថាខ័ណ្ឌទេនោះ អ្នកធានារ៉ាប់រងត្រូវ÷

(ក) កំណត់អំពីតម្លៃពិតគណនេយ្យនៃបំណុលហិរញ្ញវត្ថុពាក់ព័ន្ធ* ដកឱ្យតម្លៃពិតគណនេយ្យនៃ÷

១-ថ្លៃដើមទិញពន្យាពាក់ព័ន្ធនានា និង

២-ទ្រព្យសកម្មអរូបិយពាក់ព័ន្ធ ដូចជា ទ្រព្យសកម្មដែលបានទិញនៅក្នុងការរួមបញ្ចូលអាជីវកម្ម ឬអនុប្បទាន សម្រាប់វិនិយោគ (សូមមើលកថាខ័ណ្ឌ ៣១ និង ៣២)។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ទ្រព្យសកម្មពីការធានារ៉ាប់រងបន្ត មិនត្រូវបានយកមកពិចារណាទេ ពីព្រោះ អ្នកធានារ៉ាប់រងកត់ត្រានូវទ្រព្យសកម្មទាំងនោះដាច់ដោយឡែកពីគ្នា (សូមមើល កថាខ័ណ្ឌ ២០)។

(ខ) កំណត់ថាតើ ចំនួនទឹកប្រាក់ ដែលបានពិពណ៌នានៅក្នុងចំណុច (ក) តិចជាងតម្លៃពិតគណនេយ្យ ដែលអាចតម្រូវ ប្រសិនបើបំណុលធានារ៉ាប់រងពាក់ព័ន្ធស្ថិតនៅក្រោមវិសាលភាពនៃស្តង់ដាគណនេយ្យអន្តរជាតិលេខ ៣៧។ ប្រសិនបើវាមានចំនួនតិចតួច អ្នកធានារ៉ាប់រង ត្រូវទទួលស្គាល់នូវភាពខុសគ្នាសរុប នៅក្នុងចំណេញ-ខាត និងត្រូវកាត់បន្ថយតម្លៃពិតគណនេយ្យនៃថ្លៃដើមទិញពន្យាពាក់ព័ន្ធ ឬនៃទ្រព្យសកម្មអរូបិយពាក់ព័ន្ធ ឬបង្កើនតម្លៃពិតគណនេយ្យរបស់បំណុលធានារ៉ាប់រងពាក់ព័ន្ធ។

១៨ ប្រសិនបើ ការសាកល្បងភាពគ្រប់គ្រាន់នៃបំណុលរបស់អ្នកធានារ៉ាប់រងបំពេញបានតាមការតម្រូវអប្បបរិមានៃកថាខ័ណ្ឌ ១៦ ការសាកល្បងត្រូវបានអនុវត្តក្នុងកម្រិតមួយជារួម ដូចបានកំណត់នៅក្នុងការសាកល្បងនោះ ។ ប្រសិនបើ ការសាកល្បងភាពគ្រប់គ្រាន់នៃបំណុល មិនបំពេញបានតាម ការតម្រូវជាអប្បបរិមាទាំងនោះទេ ការប្រៀបធៀបដែលបានពិពណ៌នាក្នុង កថាខ័ណ្ឌ ១៧ មិនត្រូវបានធ្វើឡើងក្នុងកម្រិតផលបត្រនៃកិច្ចសន្យា ដែលអាចជាកម្មវត្ថុដែលមានហានិភ័យទូលាយប្រហាក់ប្រហែល និងដែលត្រូវបានគ្រប់គ្រងជាមួយគ្នាដូចជាផលបត្រតែមួយ ។

១៩ ចំនួនទឹកប្រាក់ដែលបានពិពណ៌នានៅក្នុងកថាខ័ណ្ឌ ១៧(ខ) (ដូចជាលទ្ធផលនៃការអនុវត្តស្តង់ដារគណនេយ្យលេខ ៣៧) ត្រូវបង្ហាញឱ្យឃើញនូវកម្រិតវិនិយោគ នាពេលអនាគត (សូមមើលកថាខ័ណ្ឌ ២៧-២៩) ប្រសិនបើចំនួនទឹកប្រាក់ដែលបានពិពណ៌នានៅក្នុងកថាខ័ណ្ឌ ១៧(ក) ក៏បានបង្ហាញនូវកម្រិតនោះដែរ។

## ការថយចុះតម្លៃនៃទ្រព្យសកម្មធានារ៉ាប់រងបន្ត

២០ ប្រសិនបើទ្រព្យសកម្មពីការធានារ៉ាប់រងបន្តរបស់អនុប្បទានិកត្រូវបានថយចុះតម្លៃ អនុប្បទានិក ត្រូវកាត់បន្ថយតម្លៃពិតគណនេយ្យរបស់ទ្រព្យនោះទៅតាមនោះដែរ ហើយត្រូវទទួលស្គាល់ការខាតបង់ដោយសារការថយចុះតម្លៃនៅក្នុងចំណេញ-ខាត។ ទ្រព្យសកម្មធានារ៉ាប់រងបន្ត ត្រូវបានថយចុះតម្លៃ ប្រសិនបើ និងតែក្នុងករណីបើ÷

(ក) មានភស្តុតាងអំពីគោលដៅ ដែលជាលទ្ធផលនៃព្រឹត្តិការណ៍មួយបានកើតឡើងបន្ទាប់ពីការទទួលស្គាល់លើកដំបូងលើទ្រព្យសកម្មពីការធានារ៉ាប់រងបន្ត ដែលអនុប្បទានិកអាចមិនទទួលបាននូវចំនួនទឹកប្រាក់ទាំងអស់ដោយសារតែព្រឹត្តិការណ៍នោះក្រោមលក្ខខណ្ឌនៃកិច្ចសន្យា។ និង

(ខ) ព្រឹត្តិការណ៍នោះមានផលប៉ះពាល់ដែលអាចវាស់វែងគួរឲ្យទុកចិត្តបានលើចំនួនទឹកប្រាក់ ដែលអនុប្បទានិកនឹងទទួលបាន ពីការធានារ៉ាប់រងបន្ត។

## ការប្រែប្រួលគោលនយោបាយគណនេយ្យ

២១ កថាខ័ណ្ឌ ២២-៣០ អនុវត្តចំពោះទាំងការប្រែប្រួលដែលបានធ្វើឡើងដោយអ្នកធានារ៉ាប់រង ដែលបានអនុវត្ត ស.រ.ហ.អ នានារួចហើយ និងចំពោះទាំងការប្រែប្រួលដែលបានធ្វើឡើងដោយអ្នកធានារ៉ាប់រងដែលបានអនុម័ត ស.រ.ហ.អ មកអនុវត្តលើកដំបូង។

**២២ អ្នកធានារ៉ាប់រង អាចផ្លាស់ប្តូរគោលនយោបាយគណនេយ្យរបស់ខ្លួនសម្រាប់កិច្ចសន្យាធានារ៉ាប់រងប្រសិនបើ និងតែក្នុងករណីបើ ការផ្លាស់ប្តូរនោះនាំឲ្យរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនកាន់តែមានភាពទុកចិត្តចំពោះសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់នៅក្នុងការធ្វើសេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់គេ ឬមិនធ្វើឲ្យជំនឿទុកចិត្តនោះថយចុះ ឬធ្វើឲ្យជំនឿទុកចិត្តកើនឡើងនិងមិនបន្ថយភាពជាប់ពាក់ព័ន្ធ ចំពោះសេចក្តីត្រូវការនោះ។ អ្នកធានារ៉ាប់រងត្រូវវិនិច្ឆ័យភាពជឿទុកចិត្តនិងភាពជាប់ពាក់ព័ន្ធដោយផ្អែកលើលក្ខណៈវិនិច្ឆ័យនៅក្នុងស្តង់ដារគណនេយ្យអន្តរជាតិលេខ ៨។**

២៣ ដើម្បីនិយ័តកម្មការផ្លាស់ប្តូរគោលនយោបាយគណនេយ្យរបស់ខ្លួនសម្រាប់កិច្ចសន្យាធានារ៉ាប់រង អ្នកធានារ៉ាប់រងត្រូវបង្ហាញថា ការផ្លាស់ប្តូរនាំឲ្យរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនកាន់តែខិតទៅរកលក្ខណៈវិនិច្ឆ័យដូចមានក្នុងស្តង់ដាគណនេយ្យអន្តរជាតិ លេខ ៨ ប៉ុន្តែការផ្លាស់ប្តូរមិនចាំបាច់ទទួលបានអនុលោមភាពទាំងស្រុង ជាមួយលក្ខណៈវិនិច្ឆ័យទាំងនោះទេ។ បញ្ហាដោយឡែកដូចខាងក្រោមត្រូវបានយកមកពិភាក្សាដូចខាងក្រោម÷

(ក) អត្រាការប្រាក់ជាក់ស្តែង (កថាខ័ណ្ឌ២៤)

(ខ) ការបន្តការអនុវត្តដែលមានស្រាប់ (កថាខ័ណ្ឌ២៥)

(គ) ការប្រុងប្រយ័ត្ន(កថាខ័ណ្ឌ២៦)

(ឃ) គម្លាតវិនិយោគនាពេលអនាគត (កថាខ័ណ្ឌ២៧-២៩) និង

(ង) ការកត់ត្រាគណនេយ្យគ្រាន់តែជានាម(កថាខ័ណ្ឌ៣០)។

### អត្រាការប្រាក់ជាក់ស្តែងលើទីផ្សារ

២៤ អ្នកធានារ៉ាប់រងត្រូវបានអនុញ្ញាត ប៉ុន្តែមិនតម្រូវ ឲ្យផ្លាស់ប្តូរ គោលនយោ-បាយគណនេយ្យរបស់ខ្លួន ដូចនេះ គេត្រូវវាស់វែងឡើង វិញនូវបំណុលធានារ៉ាប់រង ដែលបានកំណត់* ដើម្បីបង្ហាញឲ្យឃើញនូវអត្រាការប្រាក់ទីផ្សារបច្ចុប្បន្ន និងទទួលស្គាល់នូវការផ្លាស់ប្តូរលើបំណុលទាំងនោះ ក្នុងចំណេញ-ខាត។ ក្នុងពេលនោះ អ្នកធានារ៉ាប់រង ក៏អាចដាក់ឲ្យអនុវត្តនូវគោលនយោបាយគណនេយ្យ ដែលតម្រូវឲ្យមានការប៉ាន់ស្មាន និងការសន្មត់ជាក់ស្តែងសម្រាប់បំណុលដែលបានកំណត់។ ការរើសយកនៅក្នុងកថាខ័ណ្ឌនេះ អនុញ្ញាតឲ្យអ្នកធានារ៉ាប់រងផ្លាស់ប្តូរ គោលនយោបាយគណនេយ្យរបស់ខ្លួនដោយមិនគិតពីការអនុវត្តគោលនយោបាយទាំងនោះស្របតាមបំណុលប្រហាក់ប្រហែលដូចដែលស្តង់ដារគណនេយ្យអន្តរជាតិលេខ ៨ អាចតម្រូវផ្សេងពីនេះនោះទេ។ ប្រសិនបើ អ្នកធានារ៉ាប់រងកំណត់នូវបំណុលសម្រាប់ការជ្រើសរើសនេះ អ្នកធានារ៉ាប់រងត្រូវបន្តអនុវត្តអត្រាការប្រាក់ទីផ្សារជាក់ស្តែង (ហើយប្រសិនបើអាចអនុវត្តបាន ត្រូវអនុវត្តការប៉ាន់ស្មាននិងការសន្មត់ជាក់ស្តែងដទៃទៀត) ស្របទៅនឹងបំណុលទាំងអស់នេះក្នុងគ្រប់ការិយបរិច្ឆេទ រហូតដល់បំណុលទាំងនោះត្រូវបានរំលត់។

### ការបន្តការប្រតិបត្តិដែលធ្លាប់ធ្វើកន្លងមក

២៥ អ្នកធានារ៉ាប់រង អាចបន្តការអនុវត្តកន្លងមកដូចខាងក្រោម ប៉ុន្តែការដាក់ឲ្យអនុវត្តណាមួយនោះ មិនបំពេញបានតាមកថាខ័ណ្ឌ ២២ នោះទេ÷

(ក) ការវាស់វែងបំណុលធានារ៉ាប់រងតាមមូលដ្ឋានមិនអប្បហា

(ខ) ការវាស់វែងសិទ្ធិតាមកិច្ចសន្យាលើតម្លៃគ្រប់គ្រងវិនិយោគនាពេលអនាគត តាមបរិមាណទឹកប្រាក់មួយលើសពី តម្លៃទីផ្សាររបស់វាដូចដែលបានកំណត់ដោយការប្រៀបធៀបជាមួយតម្លៃជាក់ស្តែងដែលយក ដោយអ្នកចូលរួមក្នុងទីផ្សារដទៃទៀត សម្រាប់សេវាស្រដៀងគ្នា។ វាប្រហែលជាថាតម្លៃទីផ្សារនាពេលទទួលយកសិទ្ធិតាមកិច្ចសន្យាស្មើនឹងថ្លៃដើមដំបូងដែលបានចំណាយ វាលែងតែតម្លៃគ្រប់គ្រងវិនិយោគនាពេលអនាគត និងថ្លៃដើមពាក់ព័ន្ធ មានលក្ខណៈមិនសមរម្យជាមួយទីផ្សារដែលអាចប្រៀបធៀបបាន។

(គ) ការប្រើប្រាស់គោលនយោបាយគណនេយ្យមិនឯកភាពគ្នាសម្រាប់កិច្ចសន្យាធានារ៉ាប់រង (និងថ្លៃដើមទិញពន្យាពាក់ព័ន្ធនិង ទ្រព្យសកម្ម អរូបិយពាក់ព័ន្ធ ប្រសិនបើមាន) របស់អង្គភាពបុត្រសម្ព័ន្ធលើកលែងតែមានការអនុញ្ញាត ដូចមាន ក្នុងកថាខ័ណ្ឌ ២៤។ ប្រសិនបើគោលនយោបាយគណនេយ្យទាំងនោះមិនមានលក្ខណៈឯកភាពគ្នាទេ អ្នកធានារ៉ាប់រងអាចផ្លាស់ប្តូរគោលនយោបាយទាំងនោះ ប្រសិនបើ ការផ្លាស់ប្តូរមិនបានធ្វើឲ្យ គោលនយោបាយគណនេយ្យមានភាពផ្សេងៗគ្នាកាន់តែខ្លាំង និងក៏បំពេញតាមការតម្រូវដទៃទៀតនៅក្នុង ស.រ.ហ.អ នេះ។

## ការប្រុងប្រយ័ត្ន

២៦ អ្នកធានារ៉ាប់រង មិនចាំបាច់ផ្លាស់ប្តូរគោលនយោបាយគណនេយ្យរបស់ខ្លួនសម្រាប់កិច្ចសន្យាធានារ៉ាប់រង ដើម្បីលុបចោលការប្រុងប្រយ័ត្នហួសហេតុនោះទេ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើ អ្នកធានារ៉ាប់រងវាស់

វែងរួចហើយនូវកិច្ចសន្យាធានារ៉ាប់រងរបស់ខ្លួនដោយមានការប្រុងប្រយ័ត្នគ្រប់គ្រាន់ នោះអ្នកធានារ៉ាប់រងមិនត្រូវដាក់ឲ្យអនុវត្តការប្រុងប្រយ័ត្នបន្ថែមទៀតទេ។

## គម្លាតវិនិយោគនាពេលអនាគត

២៧ អ្នកធានារ៉ាប់រង មិនចាំបាច់ផ្លាស់ប្តូរគោលនយោបាយគណនេយ្យរបស់ខ្លួនសម្រាប់កិច្ចសន្យាធានារ៉ាប់រង ដើម្បីលុបចោលគម្លាតវិនិយោគ នាពេលអនាគតនោះទេ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏មានការសន្មតដែលគេនិយមមួយ ដែលរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកធានារ៉ាប់រងនឹងក្លាយទៅជាមិនមានការទាក់ទិននិងមិនគួរឲ្យជឿជាក់ ប្រសិនបើ អ្នកធានារ៉ាប់រងអនុវត្តគោលនយោបាយគណនេយ្យដែលបង្ហាញឲ្យឃើញនូវគម្លាតវិនិយោគនាពេលអនាគតនៅក្នុងការវាស់វែងកិច្ចសន្យាធានារ៉ាប់រង វាលែងតែគម្លាតទាំងនោះប៉ះពាល់ដល់ ការទូទាត់តាមកិច្ចសន្យា។ ឧទាហរណ៍ ២ នៃគោលនយោបាយគណនេយ្យ ដែលបង្ហាញឲ្យឃើញនូវគម្លាតទាំងនោះ÷

(ក) ការប្រើអត្រាអប្បហា ដែលបង្ហាញឲ្យឃើញប្រាក់ចំណូលប៉ាន់ស្មានពីទ្រព្យសកម្មរបស់អ្នកធានារ៉ាប់រង។ ឬ

(ខ) ការគ្រោងនូវចំណូលពីទ្រព្យសកម្មទាំងនោះ តាមអត្រាចំណូលប៉ាន់ស្មាន ដោយបញ្ចុះតម្លៃចំណូលដែលបានគ្រោងតាមអត្រាខុសគ្នាមួយ និងដោយបញ្ចូល នូវលទ្ធផលនៅក្នុងការវាស់វែងបំណុល។

២៨ អ្នកធានារ៉ាប់រង អាចព្យាយាមទទួលយកការសន្មត់ដែលគេនិយមដូចដែលបានពិពណ៌នានៅក្នុងកថាខ័ណ្ឌ ២៧ ប្រសិនបើសមាធាតុដទៃទៀតនៃការផ្លាស់ប្ដូរគោលនយោបាយគណនេយ្យ បង្កើននូវភាពជាប់ទាក់ទិននិងជំនឿទុកចិត្តលើរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដែលមានលក្ខណៈគ្រប់គ្រាន់សម្រាប់ធ្វើឱ្យការថយចុះកាន់តែខ្លាំងនៃភាពជាប់ពាក់ព័ន្ធនិងជំនឿទុកចិត្តដែលបណ្ដាលមកពីការដកចេញនូវ គម្លាតវិនិយោគ នាពេលអនាគត។ ឧទាហរណ៍ សន្មតថា គោលនយោបាយគណនេយ្យរបស់អ្នកធានារ៉ាប់រងសម្រាប់កិច្ចសន្យាធានារ៉ាប់រង ពាក់ព័ន្ធហួសហេតុទៅនឹងការសន្មត់ ដែលមានការប្រុងប្រយ័ត្នដែលបានធ្វើឡើងនាពេលចាប់ផ្ដើម និងពាក់ព័ន្ធទៅនឹងអត្រាអប្បហា ដែលបានពិពណ៌នាដោយនិយ័តករ ដោយមិនយោងដោយផ្ទាល់ ចំពោះលក្ខខណ្ឌទីផ្សារ ព្រមទាំងមិនយកចិត្តទុកដាក់ អំពីជម្រើស និងការធានាបង្កប់។ អ្នកធានារ៉ាប់រង អាចធ្វើឱ្យរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនកាន់តែមានភាពជាប់ពាក់ព័ន្ធ និងជំនឿទុកចិត្ត ដោយប្ដូរទៅជាមូលដ្ឋានគណនេយ្យទូលាយដែលដៅចំពោះវិនិយោគិន ដែលត្រូវបានប្រើប្រាស់យ៉ាងទូលាយ និងទាក់ទិនទៅនឹង÷

(ក) ការប៉ាន់ស្មាននិងការសន្មត់ជាក់ស្ដែង

(ខ) ការកែតម្រូវសមស្រប (ប៉ុន្តែមិនមានការប្រុងប្រយ័ត្នហួសហេតុនោះទេ) ដើម្បីបង្ហាញឱ្យឃើញនូវហានិភ័យនិងភាពមិនប្រាកដប្រជា

(គ) ការវាស់វែងដែលបង្ហាញឱ្យឃើញទាំងតម្លៃបង្កប់ និងតម្លៃពេលវេលានៃជម្រើសនិងការធានាបង្កប់។ និង

(ឃ) អត្រាអប្បហាទីផ្សារជាក់ស្តែង ទោះបីជាអត្រាអប្បហានោះបង្ហាញអំពីចំណូលប៉ាន់ស្មានពីទ្រព្យសកម្មរបស់អ្នកធានារ៉ាប់រងក៏ដោយ។

២៩ នៅក្នុងទស្សនទាននៃការវាស់វែងខ្លះ អត្រាអប្បហា ត្រូវបានប្រើប្រាស់ដើម្បីកំណត់អំពីតម្លៃជាក់ស្តែងនៃប្រាក់ចំណេញនាពេលអនាគត។ ដូចនេះ គម្លាតប្រាក់ចំណេញនោះ នាំឲ្យមានការប្រើរូបមន្តខុសគ្នា តាមការិយ-បរិច្ឆេទ ។ តាមទស្សនៈទាំងនោះ អត្រាអប្បហា មានឥទ្ធិពលដោយផ្ទាល់តែលើការវាស់វែងបំណុលប៉ុណ្ណោះ។ ជាពិសេស ការប្រើប្រាស់អត្រាអប្បហាសមស្របតិចតួច មានឥទ្ធិពលកំណត់មួយឬមិនមានឥទ្ធិពលលើការវាស់វែងបំណុលនាពេលចាប់ផ្តើម។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយក៏នៅក្នុងទស្សនៈទានខ្លះ អត្រាអប្បហាកំណត់ អំពីការវាស់វែងបំណុលដោយផ្ទាល់។ ក្នុងករណីចុងក្រោយនេះ ដោយសារតែការចាប់ផ្តើមអនុវត្តអត្រាអប្បហាដោយផ្អែកលើមូលដ្ឋានទ្រព្យសកម្មមានឥទ្ធិពលកាន់តែខ្លាំងអ្នកធានារ៉ាប់រង ទំនងជាទទួលយកការសន្មត់ដែលពេញនិយម ដូចបានកំណត់នៅក្នុងកថាខ័ណ្ឌ ២៧។

## ការកត់ត្រាគណនេយ្យជានាម

៣០ នៅក្នុងម៉ូដែលនៃការកត់ត្រាគណនេយ្យខ្លះ ការសម្រេចបាននូវចំណេញខាតពីទ្រព្យសកម្មរបស់អ្នកធានារ៉ាប់រង មានឥទ្ធិពលដោយផ្ទាល់លើការវាស់វែងមួយចំនួនឬទាំងអស់នៃ (ក)-បំណុលធានារ៉ាប់រងរបស់គេ, (ខ)-ថ្លៃដើមទិញពន្យាពាក់ព័ន្ធ និង (គ)-ទ្រព្យសកម្មអរូបិយពាក់ព័ន្ធ ដូចជាទ្រព្យសកម្មដែលបានពិពណ៌នានៅក្នុងកថាខ័ណ្ឌ ៣១ និង៣២។ អ្នកធានារ៉ាប់រងត្រូវបានអនុញ្ញាត ប៉ុន្តែមិនតម្រូវ ឲ្យផ្លាស់ប្តូរគោលនយោបាយ

គណនេយ្យរបស់ខ្លួន ដូចនេះ ចំណេញ-ខាតដែលបានទទួលស្គាល់ ប៉ុន្តែមិនទទួលបានពីទ្រព្យសកម្មមួយ មានឥទ្ធិពលលើ ការវាស់វែងទាំងនោះតាមមធ្យោបាយដូចគ្នាដែលធ្វើជាមួយចំណេញ-ខាត ដែលទទួលបានមកវិញ។ ការកែតម្រូវពាក់ព័ន្ធចំពោះបំណុលធានារ៉ាប់រង (ឬចំពោះថ្លៃដើមទិញពន្យា ឬទ្រព្យសកម្មអរូបិយ) ត្រូវតែបានទទួលស្គាល់ នៅក្នុងរបាយការណ៍ លទ្ធផលដទៃទៀត ប្រសិនបើ និងតែប្រសិនបើ ចំណេញ-ខាតដែលមិនទទួលបានវិញ ត្រូវបានទទួលស្គាល់ក្នុង របាយការណ៍លទ្ធផលដទៃទៀត។ ការអនុវត្តបែបនេះ ជួនកាលត្រូវបានគេហៅថា “ ការកត់ត្រាគណនេយ្យជានាម ”។

## កិច្ចសន្យាធានារ៉ាប់រងដែលបានទិញតាមរយៈការរួមបញ្ចូលអាជីវកម្ម ឬអនុប្បទានផលបត្រ

៣១ ដើម្បីឱ្យស្របតាម ស.រ.ហ.អ លេខ ៣ នាកាលបរិច្ឆេទទិញ អ្នកធានារ៉ាប់រងត្រូវវាស់វែងតម្លៃទីផ្សារនូវបំណុលធានារ៉ាប់រងដែលបានសន្មត់ និង *ទ្រព្យសកម្មធានារ៉ាប់រង* ដែលបានទិញ នៅក្នុងការរួមបញ្ចូលអាជីវកម្ម។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏អ្នកធានារ៉ាប់រងត្រូវបានអនុញ្ញាត ប៉ុន្តែមិនតម្រូវឱ្យប្រើការបង្ហាញទូលំទូលាយដែលបំបែកតម្លៃទីផ្សារនៃកិច្ចសន្យាធានារ៉ាប់រងដែលបានទិញជាពីរសមាសធាតុ÷

(ក) បំណុលដែលបានវាស់វែងស្របតាមគោលនយោបាយគណនេយ្យរបស់អ្នកធានារ៉ាប់រង សម្រាប់កិច្ចសន្យាធានារ៉ាប់រងដែលគេបានចេញ និង

(ខ) ទ្រព្យសកម្មអរូបិយ ដែលតំណាងឲ្យភាពខុសគ្នានៃ ១-តម្លៃទីផ្សារនៃសិទ្ធិលើធានារ៉ាប់រងដែលបានទិញតាមកិច្ចសន្យានិងកាតព្វកិច្ចតាមកិច្ចសន្យាដែលបានសន្មត់ និង ២-ចំនួនទឹកប្រាក់ដែលបានពិពណ៌នា នៅក្នុងចំណុច (ក)។ ការវាស់វែងជាបន្តបន្ទាប់នៃទ្រព្យសកម្មនោះ ត្រូវតែស្របជាមួយនឹងការវាស់វែងបំណុលធានារ៉ាប់រងពាក់ព័ន្ធ។

៣២ អ្នកធានារ៉ាប់រងដែលទិញផលបត្រនៃកិច្ចសន្យាធានារ៉ាប់រង អាចប្រើការបង្ហាញទូលំទូលាយ ដូចបានបង្ហាញនៅក្នុងកថាខ័ណ្ឌ ៣១។

៣៣ ទ្រព្យសកម្មអរូបិយដែលបានពិពណ៌នានៅក្នុងកថាខ័ណ្ឌ ៣១ និង ៣២ ត្រូវបានដកចេញពីវិសាលភាពនៃ ស្តង់ដាគណនេយ្យអន្តរជាតិលេខ ៣៦ ស្តីពី*ការថយចុះតម្លៃនៃទ្រព្យសកម្ម* និងស្តង់ដាគណនេយ្យអន្តរជាតិលេខ ៣៨។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏ស្តង់ដារលេខ ៣៦ និង ៣៨ អនុវត្តចំពោះបញ្ជីអតិថិជន និងទំនាក់ទំនងអតិថិជន ដែលបង្ហាញអំពីការរំពឹងទុកនៃកិច្ចសន្យា នាពេលអនាគត ដែលមិនមែនជាផ្នែកមួយនៃសិទ្ធិធានារ៉ាប់រងតាមកិច្ចសន្យានិងកាតព្វកិច្ចធានារ៉ាប់រងតាមកិច្ចសន្យា ដែលបានកើតមាននាកាលបរិច្ឆេទនៃការរួមបញ្ចូលអាជីវកម្ម ឬការផ្ទេរមូលបត្រនោះទេ។

## លក្ខណៈពិសេសនៃការចូលរួមសម្រេចចិត្ត (ដោយឆន្ទានុសិទ្ធិ)

### លក្ខណៈពិសេសនៃការចូលរួមសម្រេចចិត្ត (ដោយឆន្ទានុសិទ្ធិ)នៅក្នុងកិច្ចសន្យាធានារ៉ាប់រង

៣៤ កិច្ចសន្យាធានារ៉ាប់រងមួយចំនួន មានលក្ខណៈពិសេស នៃការចូលរួមសម្រេចចិត្ត (ដោយឆន្ទានុសិទ្ធិ) ក៏ដូចជាមាន*ធាតុត្រូវបានធានារ៉ាប់រង*។ អ្នកចេញកិច្ចសន្យានេះ÷

(ក) អាច ប៉ុន្តែមិនចាំបាច់ទទួលស្គាល់ធាតុ ដែលបានធានារ៉ាប់រងដាច់ដោយឡែកពីគ្នានូវលក្ខណៈពិសេស នៃការចូលរួមសម្រេចចិត្ត (ដោយឆន្ទានុសិទ្ធិ)នោះទេ។ ប្រសិនបើ អ្នកចេញកិច្ចសន្យាមិនទទួលស្គាល់នូវធាតុទាំងនោះដាច់ដោយឡែកពីគ្នាទេ គេត្រូវចាត់ថ្នាក់កិច្ចសន្យាទាំងមូលថាជាបំណុលមួយ។ ប្រសិនបើ អ្នកចេញកិច្ចសន្យាចាត់ថ្នាក់ធាតុទាំងនោះ ដាច់ដោយឡែកពីគ្នាគេត្រូវចាត់ថ្នាក់ធាតុដែលត្រូវបានធានាថាជាបំណុលមួយ។

(ខ) ប្រសិនបើ អ្នកធានារ៉ាប់រងទទួលស្គាល់ នូវលក្ខណៈពិសេស នៃការចូលរួមសម្រេចចិត្ត (ដោយឆន្ទានុសិទ្ធិ) ដាច់ដោយឡែកពីធាតុដែលត្រូវបានធានា អ្នកធានារ៉ាប់រង ត្រូវចាត់ថ្នាក់លក្ខណៈពិសេសនោះថាជាបំណុលមួយផង និងជាសមាសធាតុដោយឡែកនៃមូលធនផង។ ស.រ.ហ.អ នេះ មិនបញ្ជាក់ច្បាស់នូវវិធីដែលអ្នកចេញកិច្ចសន្យាកំណត់ថាតើ លក្ខណៈពិសេសមួយជាបំណុល ឬជាមូលធនយ៉ាងដូចម្តេចទេ។ អ្នកចេញកិច្ចសន្យា អាចបំបែកលក្ខខណៈពិសេសនោះ ជាសមាសធាតុបំណុល និងមូលធន ហើយ ត្រូវប្រើគោលនយោបាយគណនេយ្យឲ្យស្របគ្នា សម្រាប់

ការបំបែកនោះទេ។ អ្នកចេញកិច្ចសន្យា មិនត្រូវធ្វើចំណាត់ថ្នាក់លក្ខណៈពិសេសនោះជា ប្រភេទមួយនៅចន្លោះកណ្តាល ដែលមិនមែនជាបំណុល និងមិនមែនជាមូលធននោះទេ។

(គ) អាចទទួលស្គាល់នូវរាល់បុព្វលាភទាំងអស់ ដែលទទួលបានថាជាចំណូល ដោយមិនមានការបែងចែកផ្នែកណាមួយទាក់ទិននឹងសមាសធាតុមូលធននោះទេ។ ការផ្លាស់ប្តូរ ដែលទទួលបានលើធាតុដែលបានធានារ៉ាប់រងនិងលើផ្នែកនៃលក្ខណៈពិសេសនៃការចូលរួមសម្រេចចិត្ត ដែលបានចាត់ថ្នាក់ថាជាបំណុល ត្រូវបានទទួលស្គាល់ក្នុងចំណេញ-ខាត។ ប្រសិនបើ លក្ខណៈពិសេសនៃការចូលរួមសម្រេចចិត្តមួយផ្នែក ឬទាំងអស់ ត្រូវបានចាត់ថ្នាក់ជាមូលធន ផ្នែកមួយនៃចំណេញ ឬខាត អាចត្រូវបានបញ្ចូលជាលក្ខណៈពិសេស (តាមមធ្យោបាយដូចគ្នាដែលផ្នែកមួយអាចបញ្ចូលជាភាគកម្មដែលគ្មានសិទ្ធិត្រួតពិនិត្យ)។អ្នកចេញកិច្ចសន្យាត្រូវទទួលស្គាល់ផ្នែក នៃចំណេញ ឬខាត ដែលអាចបញ្ចូលជាសមាសធាតុមូលធនណាមួយ នៃលក្ខណៈពិសេស នៃការចូលរួមសម្រេចចិត្ត ថាជាការផ្តល់នូវចំណេញ ឬខាត មិនមែនថាជាចំណាយ ឬចំណូលទេ (សូមមើលស្តង់ដារគណនេយ្យអន្តរជាតិលេខ ១ ស្តីពី *ការបង្ហាញអំពីរបាយការណ៍ហិរញ្ញវត្ថុ*។

(ឃ) ប្រសិនបើ កិច្ចសន្យាមាននិស្សន្ទ បង្កប់ក្នុងវិសាលភាព នៃ ស.រ.ហ.អ លេខ ៩ អ្នកធានារ៉ាប់រងត្រូវអនុវត្ត ស.រ.ហ.អ លេខ ៩ ចំពោះនិស្សន្ទបង្កប់នោះ។

(ង) ក្នុងគ្រប់ទិដ្ឋភាព ដែលមិនបានពិពណ៌នា នៅក្នុងកថាខ័ណ្ឌ ១៤-២០ និងកថាខ័ណ្ឌ ៣៤(ក)-(ឃ) អ្នកធានារ៉ាប់រង ត្រូវបន្តគោលនយោបាយគណនេយ្យរបស់ខ្លួនដែលមានស្រាប់ វាលែងតែអ្នកធានារ៉ាប់រងបានផ្លាស់គោលនយោបាយទាំងនោះ ដើម្បីអនុវត្តតាមកថាខ័ណ្ឌ ២១-៣០។

## លក្ខណៈពិសេសនៃការចូលរួមសម្រេចចិត្ត (ដោយឆន្ទានុសិទ្ធិ) លើឧបករណ៍ហិរញ្ញវត្ថុ

៣៥ ការតម្រូវនៅក្នុងកថាខ័ណ្ឌ ៣៤ ក៏ត្រូវអនុវត្តចំពោះឧបករណ៍ហិរញ្ញវត្ថុដែលមានលក្ខណៈពិសេសនៃការចូលរួមសម្រេចចិត្ត (ដោយឆន្ទានុសិទ្ធិ)។ បន្ថែមពីលើនេះ÷

(ក) ប្រសិនបើអ្នកចេញកិច្ចសន្យាចាត់ថ្នាក់លក្ខណៈពិសេសនៃការចូលរួមសម្រេចចិត្ត (ដោយឆន្ទានុសិទ្ធិ) ទាំងស្រុងថាជាបំណុលមួយអ្នកចេញកិច្ចសន្យា ត្រូវអនុវត្តការសាកល្បងភាពគ្រប់គ្រាន់នៃបំណុលដូចមានក្នុងកថាខ័ណ្ឌ ១៥-១៩ ចំពោះកិច្ចសន្យាទាំងមូល (គឺថាទាំងធាតុដែលបានធានា និងទាំងលក្ខណៈពិសេស នៃការចូលរួមសម្រេចចិត្ត (ដោយឆន្ទានុសិទ្ធិ)។ អ្នកចេញកិច្ចសន្យាមិនចាំបាច់ កំណត់ចំនួនទឹកប្រាក់ ដែលអាចបានពីការអនុវត្ត ស.រ.ហ.អ លេខ ៩ ចំពោះធាតុដែលបានធានា។

(ខ) ប្រសិនបើអ្នកចេញកិច្ចសន្យា ចាត់ថ្នាក់ផ្នែកមួយឬទាំងស្រុងនៃលក្ខណៈពិសេសនោះថាជា ធាតុដាច់ដោយឡែក នៃមូលធនបំណុល ដែលបានទទួលស្គាល់ សម្រាប់កិច្ចសន្យាទាំងមូល មិន

ត្រូវតិចជាងចំនួនទឹកប្រាក់ ដែលអាចជាលទ្ធផល នៃការអនុវត្ត ស.រ.ហ.អ លេខ ៩ ចំពោះធាតុដែលបានធានា។ ចំនួនទឹកប្រាក់នោះ រួមបញ្ចូលនូវតម្លៃបង្កប់នៃជម្រើសជុំវិញកិច្ចសន្យា ប៉ុន្តែមិនចាំបាច់បញ្ចូលតម្លៃពេលវេលានោះទេ ប្រសិនបើកថាខ័ណ្ឌ ៩ ដកចេញនូវជម្រើសនោះ ពីការវាស់វែងតាមតម្លៃទីផ្សារ។ អ្នកចេញកិច្ចសន្យា មិនចាំបាច់លាតត្រដាងព័ត៌មាន អំពីចំនួនទឹកប្រាក់ដែលអាចចេញពីការអនុវត្ត ស.រ.ហ.អ លេខ ៩ ចំពោះធាតុដែលបានធានា និងមិនចាំបាច់ឲ្យគេបង្ហាញចំនួនទឹកប្រាក់ដាច់ដោយឡែកពីគ្នា។ ម៉្យាងវិញទៀត អ្នកចេញកិច្ចសន្យា មិនចាំបាច់កំណត់នូវចំនួនទឹកប្រាក់ ប្រសិនបើ បំណុលសរុបដែលបានទទួលស្គាល់មានបរិមាណលើសយ៉ាងច្បាស់។

(គ) ទោះបីជាកិច្ចសន្យាទាំងនោះ គឺជាឧបករណ៍ហិរញ្ញវត្ថុ អ្នកចេញកិច្ចសន្យា អាចបន្តទទួលស្គាល់បុព្វលាភសម្រាប់កិច្ចសន្យាទាំងនោះថាជាចំណូល និងទទួលស្គាល់ថាជាចំណាយ ដែលកើតពីកំណើននៃតម្លៃពិតគណនេយ្យរបស់បំណុល។

(ឃ) ទោះបីជាកិច្ចសន្យាទាំងនោះគឺជាឧបករណ៍ហិរញ្ញវត្ថុ អ្នកចេញកិច្ចសន្យាដែលអនុវត្តកថាខ័ណ្ឌ ២០(ខ) នៃ ស.រ.ហ.អ លេខ ៧ ចំពោះកិច្ចសន្យានានា ដែលមានលក្ខណៈពិសេសនៃការចូលរួមសម្រេចចិត្ត (ដោយឆន្ទានុសិទ្ធិ) ត្រូវលាតត្រដាងព័ត៌មានអំពីចំណាយលើការប្រាក់សរុបដែលបានទទួលស្គាល់នៅក្នុងចំណេញ-ខាត ប៉ុន្តែមិនចាំបាច់គណនាចំណាយការប្រាក់នេះ ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

ការពន្យល់អំពីចំនួនទឹកប្រាក់ដែលបានទទួលស្គាល់

៣៦ **អ្នកធានារ៉ាប់រង ត្រូវលាតត្រដាងព័ត៌មានដែលបញ្ជាក់និងពន្យល់អំពីចំនួនទឹកប្រាក់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនដែលកើតពីកិច្ចសន្យាធានារ៉ាប់រង។**

៣៧ ដើម្បីសម្របតាមកថាខ័ណ្ឌ ៣៦ អ្នកធានារ៉ាប់រងត្រូវលាតត្រដាងព័ត៌មានៈ

(ក) គោលនយោបាយគណនេយ្យសម្រាប់កិច្ចសន្យាធានារ៉ាប់រង និងទ្រព្យសកម្មពាក់ព័ន្ធ បំណុល និងចំណាយ។

(ខ) ទ្រព្យសកម្មដែលបានទទួលស្គាល់ បំណុល ចំណូល និងចំណាយ (និងលំហូរសាច់ប្រាក់ ប្រសិនបើ វាបង្ហាញអំពីស្ថានភាពនៃលំហូរសាច់ប្រាក់ដោយប្រើវិធីសាស្ត្រផ្ទាល់)ដែលកើតពីកិច្ចសន្យាធានារ៉ាប់រង។ ម៉្យាងទៀត ប្រសិនបើអ្នកធានារ៉ាប់រងគឺជាអនុប្បទានិក គេត្រូវលាត្រដាងព័ត៌មាន÷

១- ចំណេញនិងខាតដែលបានទទួលស្គាល់នៅក្នុងចំណេញ- ខាត ក្នុងការទិញធានារ៉ាប់រងបន្ត និង

២- ការរំលស់សម្រាប់ការិយបរិច្ឆេទ និងចំនួនទឹកប្រាក់ដែលនៅសល់មិនបានរំលស់នាដើមនិងចុងការិយបរិច្ឆេទ ប្រសិនបើអនុប្បទានិកពន្យា និងរំលស់ចំណេញ និងខាតដែលកើតពីការទិញធានារ៉ាប់រងបន្ត។

(គ) ដំណើរការដែលប្រើដើម្បីកំណត់អំពីការសន្មត់នានា ដែលមានអានុភាពខ្លាំងលើការវាស់វែង នៃចំនួនទឹកប្រាក់ ដែលបានទទួលស្គាល់ដូចមានពិពណ៌នានៅក្នុងកថាខ័ណ្ឌ (ខ)។ នៅពេលដែល

អាចអនុវត្តបាន អ្នកធានារ៉ាប់រង ក៏ត្រូវធ្វើការលាតត្រដាង ជាបរិមាណនៃការសន្មត់តាំងនោះ។

(ឃ) ឥទ្ធិពលនៃការផ្លាស់ប្តូរលើការសន្មត់ដែលបានប្រើដើម្បីវាស់វែងទ្រព្យសកម្មធានារ៉ាប់រង និងបំណុលធានារ៉ាប់រង ដោយបង្ហាញដាច់ដោយឡែកអំពីឥទ្ធិពល នៃការផ្លាស់ប្តូរនីមួយៗ ដែលមានឥទ្ធិពលខ្លាំងលើលើរបាយការណ៍ហិរញ្ញវត្ថុ។

(ង) ការផ្ទៀងផ្ទាត់ នៃការប្រែប្រួលលើបំណុលធានារ៉ាប់រង ទ្រព្យសកម្មធានារ៉ាប់រងបន្ត និងថ្លៃដើមទិញពន្យាពាក់ព័ន្ធ ប្រសិនបើមាន។

**ចរិកលក្ខណៈនិងទំហំនៃហានិភ័យដែលកើតឡើងពីកិច្ចសន្យាធានារ៉ាប់រង**

៣៨ **អ្នកធានារ៉ាប់រងត្រូវលាតត្រដាងព័ត៌មាន ដែលអាចឱ្យអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីវាយតម្លៃលើចរិកលក្ខណៈ និងទំហំហានិភ័យដែលកើតពីកិច្ចសន្យាធានារ៉ាប់រង។**

៣៩ ដើម្បីឱ្យស្របតាមកថាខ័ណ្ឌ ៣៨ អ្នកធានារ៉ាប់រងត្រូវលាតត្រដាង នូវព័ត៌មាន÷

(ក) គោលដៅ គោលនយោបាយ និងដំណើរការនានាសម្រាប់គ្រប់គ្រងហានិភ័យ ដែលកើតពីកិច្ចសន្យាធានារ៉ាប់រង និងវិធីសាស្ត្រដែលប្រើដើម្បីគ្រប់គ្រងហានិភ័យទាំងនោះ។

(ខ) (លុបចោល)

(គ) ព័ត៌មានអំពី*ហានិភ័យធានារ៉ាប់រង* (ទាំងមុននិងទាំងក្រោយពេលដែលហានិភ័យ បានធូរស្បើយដោយការធានារ៉ាប់រងបន្ត) រួមបញ្ចូលទាំងព័ត៌មានអំពី÷

១-វេទយិតភាពចំពោះហានិភ័យធានារ៉ាប់រង (សូមមើលកថាខ័ណ្ឌ ៣៩(ក))។

២-ការប្រមូលផ្តុំហានិភ័យធានារ៉ាប់រងរួមបញ្ចូលទាំងការពិពណ៌នាអំពីវិធីដែលអ្នកគ្រប់គ្រងកំណត់អំពីការប្រមូលផ្តុំ និងការពិពណ៌នាអំពីចរិកលក្ខណៈដែលបញ្ជាក់អំពីការប្រមូលផ្តុំនីមួយៗ (ដូចជាប្រភេទនៃព្រឹត្តិការណ៍ដែលបានធានា តំបន់ភូមិសាស្រ្ត ឬរូបិយប័ណ្ណ)។

៣-ការទាមទារជាក់ស្តែង បើប្រៀបធៀបជាមួយ ការប៉ាន់ស្មានមុនៗ (ដូចជា ការបង្កើតការទាមទារ)។ ការលាតត្រដាងព័ត៌មានអំពីការបង្កើតការទាមទារ ត្រូវតែត្រឡប់ទៅរកការិយបរិច្ឆេទ នៅពេលដែលការទាមទារធំចុងក្រោយបង្អស់បានកើតឡើង ដែលវានៅតែមានភាពមិនប្រាកដប្រជាអំពីចំនួនទឹកប្រាក់និងពេលវេលានៃការទូទាត់ចំពោះការទាមទារ ប៉ុន្តែមិនចាំបាច់វិលទៅរកជាង ១០ ឆ្នាំមុននោះទេ។ អ្នកធានារ៉ាប់រង មិនចាំបាច់លាតត្រដាងព័ត៌មាននេះសម្រាប់ការទាមទារ ដែលមានភាពមិនប្រាកដប្រជានៃចំនួនទឹកប្រាក់និងពេលវេលានៃការទូទាត់ការទាមទារ ត្រូវបានដោះស្រាយក្នុងរយៈពេល ០១ ឆ្នាំ។

(ឃ) ព័ត៌មានអំពី ហានិភ័យឥណទាន ហានិភ័យសាច់ប្រាក់ និងហានិភ័យទីផ្សារ ដែលកថាខ័ណ្ឌ ៣១-៤២ នៃ ស.រ.ហ.អ លេខ ៧ អាចតម្រូវ ប្រសិនបើកិច្ចសន្យាធានារ៉ាប់រង គឺស្ថិតនៅក្នុងវិសាលភាពនៃ ស.រ.ហ.អ លេខ ៧។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏÷

១-អ្នកធានារ៉ាប់រងមិនចាំបាច់ផ្តល់នូវការវិភាគអំពីការដល់ពេលវេលាកំណត់ដែលតម្រូវដោយកថាខ័ណ្ឌ ៣៩(ក) និង (ខ) នៃ ស.រ.ហ.អ លេខ ៧ នោះទេ ប្រសិនបើអ្នកធានារ៉ាប់រងនោះលាតត្រដាងព័ត៌មានអំពីពេលវេលាដែលបានប៉ាន់ស្មាននៃលំហូរចេញនៃសាច់ប្រាក់សរុបដែលបណ្តាលមកពីបំណុលធានារ៉ាប់រង។ នេះអាចត្រូវបានធ្វើឡើងក្នុងទម្រង់ជាការវិភាគលើចំនួនទឹកប្រាក់ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុតាមរយៈការកំណត់ពេលវេលាដែលបានប៉ាន់ស្មាន។

២-ប្រសិនបើ អ្នកធានារ៉ាប់រងប្រើប្រាស់វិធីសាស្ត្រ ដែលមានជម្រើសដើម្បីគ្រប់គ្រងវេទយិតភាព នៃលក្ខខណ្ឌទីផ្សារ ដូចជាការវិភាគតម្លៃបង្កប់ អ្នកធានារ៉ាប់រងអាចប្រើប្រាស់ការវិភាគលើវេទយិតភាពនោះ ដើម្បីបំពេញបាន តាមការតម្រូវ នៅក្នុងកថាខ័ណ្ឌ ៤០(ក) នៃ ស.រ.ហ.អ លេខ ៧។ អ្នកធានារ៉ាប់រងនោះក៏ត្រូវផ្តល់នូវការលាតត្រដាងព័ត៌មានដែលតម្រូវដោយកថាខ័ណ្ឌ ៤១ នៃស.រ.ហ.អ លេខ ៧ ផងដែរ។

(គ) ព័ត៌មានអំពីការផ្សាយដល់ហានិភ័យទីផ្សារ ដែលកើតពីនិស្សន្ទបង្កប់ដែលមាននៅក្នុងកិច្ចសន្យាធានារ៉ាប់រង ដែលបានធ្វើឡើង ប្រសិនបើអ្នកធានារ៉ាប់រងមិនត្រូវបានតម្រូវ និងមិនត្រូវវាស់វែងនូវនិស្សន្ទបង្កប់តាមតម្លៃទីផ្សារ។

៣៩ក ដើម្បីឲ្យស្របតាមកថាខ័ណ្ឌ ៣៩(គ)១ អ្នកធានារ៉ាប់រងត្រូវលាតត្រដាងព័ត៌មានទាំងនៅក្នុង (ក) និងទាំងក្នុង (ខ) ដូចខាងក្រោម÷

(គ) ការវិភាគអំពីវេទយិតភាពដែលបង្ហាញអំពីថាតើចំណេញ ឬខាត និងមូលធនអាចទទួលរងឥទ្ធិពលឬទេ ប្រសិនបើ ការប្រែប្រួលលើអថេរហានិភ័យពាក់ព័ន្ធដែលប្រហែលជាអាចបានកើតមានឡើងនាចុងការិយបរិច្ឆេទរាយការណ៍ ការប្រែប្រួលលើវិធីសាស្ត្រនិងការសន្មត់ ដែលបានប្រើក្នុងការរៀបចំការវិភាគ លើវេទយិត-ភាព និងប្រសិនបើមានការប្រែប្រួលពីការិយបរិច្ឆេទមុនៗ លើវិធីសាស្ត្រនិងការសន្មត់ដែលបានប្រើ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើ អ្នកធានារ៉ាប់រងប្រើវិធីសាស្ត្រ ដែលមានជម្រើស ដើម្បីគ្រប់គ្រងវេទយិតភាពចំពោះលក្ខខណ្ឌទីផ្សារ ដូចជាការវិភាគលើតម្លៃបង្កប់ វាអាចបំពេញបានតាមការតម្រូវដោយការលាតត្រដាងនូវការវិភាគវេតយិតភាពដែលមានជម្រើសនោះនិងការលាតត្រដាងព័ត៌មានដែលតម្រូវដោយកថាខ័ណ្ឌ ៤១ នៃ ស.រ.ហ.អ លេខ ៧។

(ខ) ព័ត៌មានផ្នែកគុណភាព អំពីវេទយិតភាព ព្រមទាំងព័ត៌មានអំពីពេលវេលានិងលក្ខខណ្ឌនៃកិច្ចសន្យាធានារ៉ាប់រងទាំងនោះ ដែលមានឥទ្ធិពលជាសារវន្តលើចំនួនទឹកប្រាក់ ពេលវេលា និងភាពមិនប្រាកដប្រជានៃលំហូរសាច់ប្រាក់ នាពេលអនាគតរបស់អ្នកធានារ៉ាប់រង។

## កាលបរិច្ឆេទចូលជាធរមាន និងអន្តរកាល

៤០ វិធានអន្តរកាលនៅក្នុងកថាខ័ណ្ឌ ៤១-៤៥ អនុវត្តទាំងចំពោះអង្គភាពដែលបានអនុវត្ត ស.រ.ហ.អ រួចមកហើយ នៅពេលដែលអង្គភាពនោះ

អនុវត្តលើកដំបូងនូវស្តង់ដានោះ និងទាំងចំពោះអង្គភាព ដែលទើបតែអនុវត្ត ស.រ.ហ.អ លើកដំបូង (អ្នកអនុម័តលើកដំបូង)។

៤១ អង្គភាព ត្រូវអនុវត្តស្តង់ដានេះសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំចាប់ផ្តើមបន្ទាប់ពីថ្ងៃទី ១ មករា ឆ្នាំ២០០៥។ ការអនុវត្តមុន ត្រូវបានលើកទឹកចិត្ត។ ប្រសិនបើអង្គភាពណាដែលអនុវត្តស្តង់ដារនេះមុនការិយបរិច្ឆេទខាងលើ ត្រូវលាតត្រដាងអំពីការណ៍នេះ។

៤១ក *កិច្ចសន្យាធានាហិរញ្ញវត្ថុ* (វិសោធនកម្មចំពោះ ស្តង់ដាគណនេយ្យអន្តរជាតិលេខ ៣៩ និង ស.រ.ហ.អ លេខ ៤) ដែលបានបោះផ្សាយនាខែសីហា ឆ្នាំ ២០០៥ បានធ្វើវិសោធនកម្មកថាខ័ណ្ឌ ៤(ឃ), ខ១៨(ឆ) និង ខ១៩(ជ)។ អង្គភាពត្រូវអនុវត្តវិសោធនកម្មទាំងនោះសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំ ដោយចាប់ផ្តើមពី ឬក្រោយថ្ងៃទី០១ ខែមករា ឆ្នាំ២០០៦។ ការអនុវត្តមុនត្រូវបានលើកទឹកចិត្ត។ប្រសិនបើអង្គភាពអនុវត្តវិសោធនកម្មទាំងនោះមុនការិយបរិច្ឆេទ អង្គភាពនូវត្រូវបង្ហាញអំពីការណ៍នេះ និងត្រូវអនុវត្តនូវវិសោធនកម្មពាក់ព័ន្ធទៅនឹង ស្តង់ដារគណនេយ្យអន្តរជាតិលេខ ៣៩ និងលេខ ៣២* ក្នុងពេលតែមួយ។

៤១ខ ស្តង់ដាគណនេយ្យអន្តរជាតិលេខ ១ (ដែលបានកែសម្រួលឡើងវិញក្នុងឆ្នាំ២០០៧) បានធ្វើវិសោធនកម្មវាក្យស័ព្ទដែលប្រើក្នុង ស.រ.ហ.អ នានា។ បន្ថែមលើសពីនេះ វាបានវិសោធនកម្មកថាខ័ណ្ឌ ៣០។ អង្គភាពត្រូវអនុវត្តនូវវិសោធនកម្មទាំងនោះសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំដោយចាប់ផ្តើមនៅថ្ងៃឬក្រោយថ្ងៃ១ ខែមករា ឆ្នាំ២០០៩។ ប្រសិនបើ អង្គភាពអនុវត្តស្តង់ដាគណនេយ្យអន្តរជាតិលេខ ១ (បានកែសម្រួលឡើងវិញក្នុង

ឆ្នាំ២០០៧) សម្រាប់ការិយបរិច្ឆេទដំបូងវិសោធនកម្មទាំងនោះ ត្រូវបាន អនុវត្តនាកាលបរិច្ឆេទដំបូងនោះ។

៤១គ (លុបចោល)

៤១ឃ ស.រ.ហ.អ លេខ ៩ ដែលបានចេញផ្សាយនៅខែតុលា ឆ្នាំ២០១២០ បាន ធ្វើវិសោធនកម្មកថាខ័ណ្ឌ ៣, ៤(ឃ), ៧, ៨, ១២, ៣៤(ឃ), ៣៥, ៤៥ និង B១៨-២០ និងឧបសម្ព័ន្ធ A និងបានលុបចោលកថាខ័ណ្ឌ ៤១គ។ អង្គភាព ត្រូវអនុវត្តវិសោធនកម្មទាំងនោះ នៅពេលដែលអង្គភាពនោះ អនុវត្ត ស.រ.ហ.អ លេខ ៩ ដែលបានចេញផ្សាយនៅក្នុង ខែតុលា ឆ្នាំ២០១០។

## ការលាតត្រដាងព័ត៌មាន

៤២ អង្គភាពមួយ មិនចាំបាច់បំពេញតាមការតម្រូវឲ្យ លាតត្រដាងព័ត៌មាន នៅក្នុង ស.រ.ហ.អ នេះ ចំពោះព័ត៌មានប្រៀបធៀបដែលទាក់ទិនទៅនឹង ការិយបរិច្ឆេទប្រចាំឆ្នាំដែលចាប់ផ្តើមមុនថ្ងៃ១ ខែមករា ឆ្នាំ២០០៥ លើក លែងតែការលាតត្រដាងព័ត៌មានដែលតម្រូវដោយកថាខ័ណ្ឌ ៣៧(ក) និង (ខ) អំពីគោលនយោបាយគណនេយ្យ ព្រមទាំងអំពីទ្រព្យសកម្មដែលបាន ទទួលស្គាល់ បំណុល ចំណូល និងចំណាយ (និងលំហូរសាច់ប្រាក់ ប្រសិន បើវិធីសាស្ត្រផ្ទាល់ត្រូវបានប្រើប្រាស់)។

៤៣ ប្រសិនបើមិនអាចអនុវត្តការតម្រូវដោយឡែកនៃកថាខ័ណ្ឌ១០-៣៥ ចំពោះ ព័ត៌មានប្រៀបធៀបដែលទាក់ទងដល់ការិយបរិច្ឆេទប្រចាំឆ្នាំចាប់ផ្តើមមុន ថ្ងៃទី១ ខែមករា ឆ្នាំ២០០៥ នោះអង្គភាពត្រូវលាតត្រដាងអំពីការណ៍នេះ។ ការអនុវត្តការសាកល្បងភាពគ្រប់គ្រាន់នៃបំណុល (កថាខ័ណ្ឌ ១៥-១៩)

ចំពោះការសាកល្បងភាពគ្រប់គ្រាន់ នៃបំណុលនេះ ជួនកាលមិនអាចអនុវត្តបានប៉ុន្តែវាមិនប្រាកដថា មិនអាចអនុវត្តបានចំពោះការតម្រូវដទៃទៀតនៃកថាខ័ណ្ឌ ១០-៣៥ ចំពោះព័ត៌មានប្រៀបធៀបនោះទេ។ ស្តង់ដាគណនេយ្យអន្តរជាតិលេខ ៨ ពន្យល់អំពីពាក្យថា “មិនអាចអនុវត្តបាន”។

៤៤ ក្នុងការអនុវត្តកថាខ័ណ្ឌ ៣៩(គ)៣ អង្គភាព មិនចាំបាច់លាតត្រដាងព័ត៌មានអំពីការបង្កើតការទាមទារដែលបានកើតឡើងមុនប្រាំឆ្នាំ មុនចប់ឆ្នាំហិរញ្ញវត្ថុដំបូងដែលអង្គភាពបានអនុវត្តស្តង់ដានេះ នោះទេ។ម្យ៉ាងទៀត ប្រសិនបើវាមិនអាចអនុវត្តបាន នៅពេលដែលអង្គភាពអនុវត្តស្តង់ដា នេះលើកដំបូង ដើម្បីរៀបចំព័ត៌មានអំពីការបង្កើតការទាមទារដែលបាន កើតមានមុនចាប់ផ្តើមការិយបរិច្ឆេទដំបូង ដែលអង្គភាពបង្ហាញ អំពីព័ត៌មានប្រៀបធៀបទាំងស្រុងដែលស្របទៅនឹងស្តង់ដានេះ នោះអង្គភាព ត្រូវលាតត្រដាងព័ត៌មានអំពីការណ៍នេះទេ។

## ការកំណត់ឡើងវិញអំពីទ្រព្យសម្បត្តិហិរញ្ញវត្ថុ

៤៥ ថ្វីបើមានកថាខ័ណ្ឌ ៤.៤.១ នៃ ស.រ.ហ.អ លេខ ៩ ក៏ដោយ នៅពេលដែលអ្នកធានារ៉ាប់រងម្នាក់ ផ្លាស់ប្តូរគោលនយោបាយគណនេយ្យរបស់ខ្លួនស្តីពីបំណុលធានារ៉ាប់រង អ្នកធានារ៉ាប់រងនោះ ត្រូវបានអនុញ្ញាត ប៉ុន្តែមិនតម្រូវឲ្យធ្វើការចាត់ថ្នាក់ឡើងវិញនូវទ្រព្យសកម្មហិរញ្ញវត្ថុរបស់ខ្លួនមួយចំនួន ប៉ុន្តែមិនទាំងអស់ ដូចនេះហើយទ្រព្យទាំងនោះត្រូវបានវាស់វែងតាមតម្លៃទីផ្សារ។ ការចាត់ថ្នាក់ឡើងវិញនេះ ត្រូវបានអនុញ្ញាត ប្រសិនបើអ្នកធានារ៉ាប់រងផ្លាស់ប្តូរគោលនយោបាយគណនេយ្យ នៅពេលដែលគេអនុវត្តស្តង់ដានេះលើកដំបូង និងប្រសិនបើ អ្នកធានារ៉ាប់រងធ្វើការផ្លាស់ប្តូរ

គោលនយោបាយជាបន្តបន្ទាប់ដែលអនុញ្ញាតដោយកថាខ័ណ្ឌ ២២។ ការចាត់ថ្នាក់ឡើងវិញ គឺជាការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ ហើយស្តង់ដាគណនេយ្យអន្តរជាតិអនុវត្តចំពោះវា។

## ឧបសម្ព័ន្ធ A

## អត្ថន័យពាក្យបច្ចេកទេស

*ឧបសម្ព័ន្ធនេះ ជាផ្នែកសំខាន់នៃ ស.រ.ហ.អ*

| | |
|---|---|
| អនុប្បទានិក | **អ្នកកាន់សិទ្ធិធានារ៉ាប់រង** ក្រោម**កិច្ចសន្យាធានារ៉ាប់រងបន្តមួយ** |
| សមាសធាតុប្រាក់តម្កល់ | សមាសធាតុតាមកិច្ចសន្យា ដែលមិនបានរាប់បញ្ចូលថាជានិស្សន្ទ តាម ស.រ.ហ.អ លេខ៩ និងអាចស្ថិតក្រោមវិសាលភាពនៃ ស.រ.ហ.អ លេខ៩ ប្រសិនបើវាជាឧបករណ៍ដាច់ដោយឡែក។ |
| កិច្ចសន្យាធានារ៉ាប់រងមិនផ្ទាល់ | គឺជា **កិច្ចសន្យាធានារ៉ាប់រង** ដែលមិនមែនជា **ការធានារ៉ាប់រងបន្ត** ។ |

| | |
|---|---|
| លក្ខណៈពិសេសនៃការចូលរួមក្នុងការសម្រេចចិត្ត (ដោយឆន្ទានុសិទ្ធិ) | ជាសិទ្ធិតាមកិច្ចសន្យាក្នុងការទទួលបាននូវអត្ថប្រយោជន៍បន្ថែម ជាការបំពេញបន្ថែមនូវ **អត្ថប្រយោជន៍ដែលបានធានា÷**<br>(ក)ដែលអាចជាផ្នែកសំខាន់មួយនៃអត្ថប្រយោជន៍តាមកិច្ចសន្យាសរុប។<br>(ខ)ដែលបរិមាណ នៃអត្ថប្រយោជន៍ទាំងនោះ ឬពេលវេលារបស់វា ត្រូវបានកិច្ចសន្យាផ្តល់ឆន្ទានុសិទ្ធិដល់អ្នកចេញកិច្ចសន្យា។ និង<br>(គ) ដែលជាកិច្ចសន្យាផ្អែកលើៈ<br>១-កិច្ចប្រតិបត្តិនៃបណ្តុំជាក់លាក់កិច្ចសន្យា ឬនៃប្រភេទជាក់លាក់នៃកិច្ចសន្យា<br>២-ចំណូលពីវិនិយោគលើបណ្តុំនៃទ្រព្យសកម្មរបស់អ្នកចេញកិច្ចសន្យា ដែលអាចទាញយកមកវិញនិង/ឬមិនអាចទាញយកមកវិញ។<br>៣-ចំណេញឬខាតរបស់ក្រុមហ៊ុនមួយរបស់មូលនិធិ ឬរបស់អង្គភាពដទៃទៀតដែលចេញកិច្ចសន្យា។ |
| តម្លៃទីផ្សារ | ចំនួនទឹកប្រាក់ដែលអាចបានពីការដោះដូរទ្រព្យសកម្ម ឬពីការទូទាត់បំណុល រវាងភាគី ដែលបានស្គាល់និងដែលមានបំណង នៅក្នុងប្រតិបត្តិការជាធម្មតាមួយ។ |

| | |
|---|---|
| កិច្ចសន្យាធានាហិរញ្ញវត្ថុ | ជាកិច្ចសន្យាមួយដែលតម្រូវឱ្យអ្នកចេញកិច្ចសន្យាធ្វើការទូទាត់ជាពិសេសដល់អ្នកកាន់កិច្ចសន្យាចំពោះការខាតបង់ដែលកើតឡើងដោយសារតែកូនបំណុលខកខានមិនបានធ្វើការទូទាត់ នៅពេលដល់កាលកំណត់សង ស្របតាមលក្ខខណ្ឌដំបូង ឬដែលបានកែប្រែ នៃឧបករណ៍បំណុល។ |
| ហានិភ័យហិរញ្ញវត្ថុ | ជាហានិភ័យនៃការប្រែប្រួលដែលអាចកើតមាននាពេលអនាគត នៃធាតុមួយឬច្រើនក្នុងចំណោម អត្រាការប្រាក់ ថ្លៃឧបករណ៍ហិរញ្ញវត្ថុ ថ្លៃទំនិញ អត្រាប្តូររូបិយប័ណ្ណបរទេស សន្ទស្សន៍ថ្លៃ ថ្លៃឥណទានឬសន្ទស្សន៍ឥណទាន ឬអថេរដទៃទៀត ដែលបានកើតឡើងករណីមានអថេរមិនមែនហិរញ្ញវត្ថុ ហើយដែលអថេរមិនមានជាក់លាក់ចំពោះភាគីនៃកិច្ចសន្យា។ |
| អត្ថប្រយោជន៍ដែលបានធានា | ជាការទូទាត់ឬអត្ថប្រយោជន៍ដទៃទៀតដែល **អ្នកកាន់សិទ្ធិធានារ៉ាប់រង**ឬវិនិយោគិនមានសិទ្ធិមិនមានលក្ខខណ្ឌទៅលើវា ហើយដែលមិនមែនជាកម្មវត្ថុ នៃឆន្ទានុសិទ្ធិរបស់អ្នកចេញកិច្ចសន្យា។ |
| ធាតុដែលបានធានា | ជាកាតព្វកិច្ចក្នុងការទូទាត់សង **អត្ថប្រយោជន៍ដែលបានធានា** ដែលបានបញ្ចូលក្នុងកិច្ចសន្យាមួយដែលមាន **លក្ខណៈពិសេសនៃការចូលរួមក្នុងការសម្រេចចិត្ត** |

**(ដោយឆន្ទានុសិទ្ធិ)**។

| | |
|---|---|
| ទ្រព្យសកម្មធានារ៉ាប់រង | ជាសិទ្ធិតាមកិច្ចសន្យាសរុបរបស់**អ្នកធានារ៉ាប់រង** តាមកិច្ចសន្យាធានារ៉ាប់រង។ |
| កិច្ចសន្យាធានារ៉ាប់រង | ជាកិច្ចសន្យាមួយដែលតាមនោះ ភាគីមួយ (អ្នកធានារ៉ាប់រង) យល់ព្រមទទួលយក **ហានិភ័យធានារ៉ាប់រង** ចម្បងពីភាគីមួយផ្សេងទៀត **(អ្នកកាន់សិទ្ធិធានារ៉ាប់រង)** ដោយយល់ព្រមទូទាត់សងដល់អ្នកកាន់សិទ្ធិធានារ៉ាប់រង ប្រសិនបើព្រឹត្តិការណ៍មិនប្រាកដប្រជា នាពេលអនាគតជាក់លាក់ (**ព្រឹត្តិការណ៍ដែលបានធានា**) មានឥទ្ធិពលបញ្រ្ចាសដល់ អ្នកកាន់សិទ្ធិធានារ៉ាប់រង។ (សូមមើលឧបសម្ព័ន្ធ B សម្រាប់គោលការណ៍ណែនាំ សម្រាប់និយមន័យនេះ)។ |
| បំណុលធានារ៉ាប់រង | ជាកាតព្វកិច្ចតាមកិច្ចសន្យាសរុបរបស់ **អ្នកធានារ៉ាប់រង** ក្រោម**កិច្ចសន្យាធានារ៉ាប់រង**។ |
| ហានិភ័យធានារ៉ាប់រង | ជាហានិភ័យ ក្រៅពី **ហានិភ័យហិរញ្ញវត្ថុ** ដែលបានផ្ទេរពីអ្នកកាន់កិច្ចសន្យាទៅអ្នកចេញកិច្ចសន្យា។ |
| ព្រឹត្តការណ៍ដែលបានធានា | ជាព្រឹត្តិការណ៍មិនប្រាកដប្រជានាអនាគត ដែលគ្របដណ្តប់ ដោយ**កិច្ចសន្យាធានារ៉ាប់រង** និង បង្កើត **ហានិភ័យធានារ៉ាប់រង**។ |

| | |
|---|---|
| អ្នកធានារ៉ាប់រង | ជាភាគីដែលមានកាតព្វកិច្ច តាម**កិច្ចសន្យាធានារ៉ាប់រង** សម្រាប់ទូទាត់សង **អ្នកកាន់សិទ្ធិធានារ៉ាប់រង** ប្រសិនបើ **ព្រឹត្តិការណ៍ដែលបានធានា**កើតឡើង។ |
| ការសាកល្បងភាពគ្រាប់គ្រាន់នៃបំណុល | ជាការវាយតម្លៃថាតើតម្លៃពិតគណនេយ្យនៃ **បំណុលធានារ៉ាប់រង** ចាំបាច់ត្រូវបង្កើនដែរឬទេ (ឬតម្លៃពិតគណនេយ្យនៃថ្លៃដើមទិញពាក់ព័ន្ធដែលបានពន្យាឬទ្រព្យសកម្មអរូបិយពាក់ព័ន្ធបានថយចុះ) ដោយផ្អែកលើមូលដ្ឋាននៃការពិនិត្យឡើងវិញលើលំហូរសាច់ប្រាក់ នាពេលអនាគត។ |
| អ្នកកាន់សិទ្ធិធានារ៉ាប់រង | ជាភាគីមួយ ដែលមានសិទ្ធិទទួលបាន ការទូទាត់សងក្រោម**កិច្ចសន្យាធានារ៉ាប់រង** ប្រសិនបើ **ព្រឹត្តិការណ៍ដែលបានធានា**បានកើតឡើង។ |
| ទ្រព្យសកម្មធានារ៉ាប់រងបន្ត | សិទ្ធិតាមកិច្ចសន្យាសុទ្ធរបស់ **អនុប្បទានិក** ក្រោមកិច្ចសន្យាធានារ៉ាប់រងបន្ត។ |
| កិច្ចសន្យាធានារ៉ាប់រងបន្ត | ជា**កិច្ចសន្យាធានារ៉ាប់រង** ដែលចេញដោយធានារ៉ាប់រងម្នាក់ (**អ្នកធានារ៉ាប់រងបន្ត**) ក្នុងការយល់ព្រមទូទាត់សងដល់អ្នកធានារ៉ាប់រងដទៃទៀត (**អនុប្បទានិក**) សម្រាប់ការខាតបង់នានាពីកិច្ចសន្យាមួយ ឬច្រើន ដែលចេញដោយអ្នកធានារ៉ាប់រងបន្ត។ |

| | |
|---|---|
| អ្នកធានារ៉ាប់រងបន្ត | ជាភាគីដែលមានកាតព្វកិច្ចក្រោម **កិច្ចសន្យាធានារ៉ាប់រងបន្ត** ក្នុងការទូទាត់សងចំពោះ **អនុប្បទានិក** ប្រសិនបើ **ព្រឹត្តិការណ៍ដែលបានធានា** បានកើតឡើង។ |
| ការបំបែកដាច់ពីគ្នា | ជាការកត់ត្រា នូវសមាសធាតុនានា នៃកិច្ចសន្យាមួយ ប្រសិនបើសមាសធាតុទាំងនោះជា របស់កិច្ចសន្យាដាច់ដោយឡែក។ |

## ឧបសម្ព័ន្ធ B

## និយមន័យនៃកិច្ចសន្យាធានារ៉ាប់រង

***ឧបសម្ព័ន្ធនេះគឺជាផ្នែកសំខាន់មួយនៃ ស.រ.ហ.អ***

B១ ឧបសម្ព័ន្ធនេះ ផ្ដល់នូវគោលការណ៍ណែនាំចំពោះអត្ថន័យនៃកិច្ចសន្យាធានារ៉ាប់រងដែលមានក្នុងឧបសម្ព័ន្ធ A។ វាលើកឡើងអំពីបញ្ហានានា ដូចខាងក្រោម÷

(ក) ពាក្យថា "ព្រឹត្តិការណ៍មិនប្រាកដប្រជានាពេលអនាគត" (កថាខ័ណ្ឌ B២- B៤)។

(ខ) ការទូទាត់តាមប្រភេទ( ដូចដើម) (កថាខ័ណ្ឌ B៥-B៧)។

(គ) ហានិភ័យធានារ៉ាប់រងនិងហានិភ័យដទៃទៀត (កថាខ័ណ្ឌ B៨-B១៧).

(ឃ) ឧទាហរណ៍នៃកិច្ចសន្យាធានារ៉ាប់រង (កថាខ័ណ្ឌ B១៨-B២១)

(ង) ហានិភ័យធានារ៉ាប់រងចម្បង( កថាខ័ណ្ឌ B២២-B២៨) និង

(ច) ការប្រែប្រួលនៃកម្រិតហានិភ័យធានារ៉ាប់រង (កថាខ័ណ្ឌ B២៩-B៣០)។

### ព្រឹត្តិការណ៍មិនប្រាកដប្រជានាពេលអនាគត

B២ ភាពមិនប្រាកដប្រជា (ឬហានិភ័យ) គឺជាខ្លឹមសារសំខាន់នៃកិច្ចសន្យាធានារ៉ាប់រង។ ដូចនេះ យ៉ាងហោចណាស់ចំណុចមួយនៃចំណុចខាងក្រោម គឺជាភាពមិនប្រាកដប្រជានាពេលចាប់ផ្តើមកិច្ចសន្យាធានារ៉ាប់រងមួយ÷

(ក) ថាតើ*ព្រឹត្តិការណ៍ដែលបានធានា* នឹងកើតមានឡើងឬអត់។

(ខ) នៅពេលណាវានឹងកើតឡើង។

(គ) តើអ្នកធានារ៉ាប់រងត្រូវទូទាត់សងចំនួនប៉ុន្មាន បើព្រឹត្តិការណ៍នោះកើតឡើង។

B៣ នៅក្នុងកិច្ចសន្យាធានារ៉ាប់រងមួយចំនួន ព្រឹត្តិការណ៍ដែលបានធានា គឺជាការកើតឡើងនូវការខាងបង់ក្នុងកំឡុងរយៈពេលនៃកិច្ចសន្យា ទោះបីជាការខាតបង់នោះកើតឡើងពីព្រឹត្តិការណ៍មួយដែលបានកើតមានមុនពេលចាប់ផ្តើមកិច្ចសន្យាក៏ដោយ ។ នៅក្នុងកិច្ចសន្យាធានារ៉ាប់រងខ្លះទៀត ព្រឹត្តិការណ៍ដែលបានធានា គឺជាព្រឹត្តិការណ៍ដែលកើតមានឡើងក្នុងកំឡុងពេលនៃរយៈពេលរបស់កិច្ចសន្យា ទោះបីជាការខាតបង់ជាលទ្ធផលនោះកើតឡើងបន្ទាប់ពីបញ្ចប់រយៈពេលនៃកិច្ចសន្យាក៏ដោយ។

B៤ កិច្ចសន្យាធានារ៉ាប់រងមួយចំនួន គ្របដណ្តប់នូវព្រឹត្តិការណ៍នានាដែលបានកើតឡើងរួចហើយ ប៉ុន្តែអានុភាពផ្នែកហិរញ្ញវត្ថុរបស់វានៅមានភាពមិនប្រាកដប្រជានៅឡើយ។ ឧទាហរណ៍មួយ គឺកិច្ចសន្យាធានារ៉ាប់រងបន្តដែលគ្របដណ្តប់អ្នកធានារ៉ាប់រងដោយផ្ទាល់ ចំពោះការទាមទារត្រឡប់

មកវិញ ដែលបានវាយការណ៍រួចហើយ ដោយអ្នកកាន់សិទ្ធិធានារ៉ាប់រង។ ក្នុងកិច្ចសន្យាបែបនេះ ព្រឹត្តិការណ៍ដែលបានធានា គឺជាការកើតឡើងនូវថ្លៃដើមចុងក្រោយនៃការទាមទារទាំងនោះ។

## ការទូទាត់តាមប្រភេទ (ដូចដើម)

B៥ កិច្ចសន្យាធានារ៉ាប់រងខ្លះ តម្រូវ ឬអនុញ្ញាតឱ្យធ្វើការទូទាត់តាមប្រភេទ (ដូចដើម)។ ឧទាហរណ៍ នៅពេលដែលអ្នកធានារ៉ាប់រងជំនួសវត្ថុដែលបានលួចដោយផ្ទាល់ជំនួសឱ្យការទូទាត់ជាប្រាក់ ចំពោះអ្នកកាន់សិទ្ធិធានារ៉ាប់រង។ ឧទាហរណ៍ផ្សេងទៀត គឺនៅពេលដែលអ្នកធានារ៉ាប់រងប្រើប្រាស់ពេទ្យ និងបុគ្គលិកពេទ្យរបស់ខ្លួនផ្ទាល់ ដើម្បីផ្តល់សេវាវេជ្ជសាស្ត្រតាមកិច្ចសន្យា។

B៦ មានកិច្ចសន្យាសេវាកម្មតាមថ្លៃឈ្នួលជាកំណត់មួយចំនួន ដែលក្នុងនោះកម្រិតនៃសេវាកម្ម អាស្រ័យទៅនឹងព្រឹត្តិការណ៍មិនប្រាកដប្រជា បំពេញបាននូវការកំណត់នៃកិច្ចសន្យាធានារ៉ាប់រងមួយតាម ស.រ.ហ.អ នេះ ប៉ុន្តែមិនបានកំណត់ជាវិធាននៃកិច្ចសន្យាធានារ៉ាប់រងនៅក្នុងប្រទេសមួយចំនួននោះទេ។ ឧទាហរណ៍មួយ គឺកិច្ចសន្យាថែទាំដែលក្នុងនោះអ្នកផ្តល់សេវាយល់ព្រមជួសជុលសម្ភារៈបន្ទាប់ពីខូចខាត។ ថ្លៃសេវាជួសជុល គឺផ្អែកលើមូលដ្ឋាននៃចំនួននៃការខូចខាតដែលបានរំពឹងទុក ប៉ុន្តែវាមានលក្ខណៈមិនប្រាកដប្រជាថាតើម៉ាស៊ីនណាវានឹងខូចខាត។ ការខូចខាតនៃសម្ភារៈមានឥទ្ធិពលបញ្ច្រាសទៅរកម្ចាស់របស់វាហើយកិច្ចសន្យាទូទាត់សង ចំពោះម្ចាស់នោះ (តាមប្រភេទ (ដូចដើម) ជាជាងដោយសាច់ប្រាក់)។ ឧទាហរណ៍មួយផ្សេងទៀត គឺកិច្ចសន្យាមួយសម្រាប់សេវាជួសជុលរថយន្តខូច ដែល

ក្នុងនោះ អ្នកផ្តល់សេវា យល់ព្រមផ្តល់នូវជំនួយតាមដងផ្លូវ ឬសណ្តោងរថយន្តទៅយានដ្ឋានដែលនៅក្បែរ សម្រាប់ថ្លៃឈ្នួលប្រចាំឆ្នាំកំណត់មួយ។ កិច្ចសន្យាចុងក្រោយនេះ អាចបំពេញបានតាមអត្ថន័យនៃកិច្ចសន្យាធានារ៉ាប់រង ទោះបីជាអ្នកផ្តល់សេវាមិនបានយល់ព្រមជួសជុលឬផ្លាស់ប្តូរគ្រឿងបន្លាស់ក៏ដោយ។

B៧ ដើម្បីអនុវត្តនូវ ស.រ.ហ.អ ចំពោះកិច្ចសន្យានានាដែលបានពិពណ៌នានៅក្នុងកថាខ័ណ្ឌ B៦ ហាក់ដូចជាមិនធ្ងន់ធ្ងរជាងការអនុវត្ត ស.រ.ហ.អ នានាដែលអាចអនុវត្តបាននោះទេ ប្រសិនបើ កិច្ចសន្យាបែបនោះស្ថិតនៅក្រៅវិសាលភាពនៃ ស.រ.ហ.អ នេះ÷

(ក) វាមិនទំនងជាមាននូវបំណុលធំដុំទេសម្រាប់ការខូចខាតដែលបានកើតឡើងរួចហើយ។

(ខ) ប្រសិនបើស្តង់ដាគណនេយ្យអន្តរជាតិលេខ ៨ ស្តីពី*ចំណូល* ត្រូវបានអនុវត្ត អ្នកផ្តល់សេវាកម្ម អាចទទួលស្គាល់នូវចំណូលដោយយោងលើដំណាក់កាលនៃ ការបំពេញកិច្ចសន្យា (ហើយជាកម្មវត្ថុនៃលក្ខណៈវិនិច្ឆ័យដោយឡែកដទៃទៀត)។ ទស្សនៈនោះក៏អាចទទួលយកបានដែរតាម ស.រ.ហ.អ នេះ ដែលអនុញ្ញាតឱ្យអ្នកផ្តល់សេវាកម្ម (១)-បន្តអនុវត្តគោលនយោបាយគណនេយ្យដែលមានស្រាប់របស់ខ្លួនសម្រាប់កិច្ចសន្យាទាំងនេះ វាលែងតែវាមានការពាក់ព័ន្ធនឹង ការអនុវត្ត ដែលបានហាមឃាត់ ដោយកថាខ័ណ្ឌ ១៤ និង (២)-ធ្វើឱ្យប្រសើរឡើងនូវគោលនយោបាយគណនេយ្យរបស់ខ្លួន ហើយបើធ្វើដូចនេះ ការថាខ័ណ្ឌ ២២-៣០ បានអនុញ្ញាត។

(គ) អ្នកផ្តល់សេវាកម្មពិចារណាថាតើថ្លៃដើមនៃការបំពេញកាតព្វកិច្ចតាមកិច្ចសន្យារបស់ខ្លួនក្នុងការផ្តល់សេវាលើសពីចំណូល ដែលទទួលបានជាមុនដែរឬទេ។ ដើម្បីធ្វើកិច្ចការនេះ អ្នកផ្តល់សេវាអនុវត្តការសាកល្បងភាពគ្រប់គ្រាន់នៃបំណុលដែលបានពិពណ៌នានៅក្នុងកថាខ័ណ្ឌ ១៥-១៩ នៃ ស.រ.ហ.អ នេះ។ ប្រសិនបើស្តង់ដានេះមិនបានអនុវត្តចំពោះកិច្ចសន្យាទាំងនេះទេ អ្នកផ្តល់សេវាអាចអនុវត្តស្តង់ដាគណនេយ្យអន្តរជាតិលេខ ៣៧ ដើម្បីកំណត់ថាតើកិច្ចសន្យាមានលក្ខណៈស្មុគ្រស្មាញដែរនោះទេ។

(ឃ) សម្រាប់កិច្ចសន្យាទាំងនេះ ការតម្រូវឲ្យលាតត្រដាងព័ត៌មាននៅក្នុងស្តង់ដារនេះ ប្រហែលជាមិនបន្ថែមនូវចំណុចសំខាន់ នៃការលាតត្រដាងព័ត៌មានដែលតម្រូវដោយ ស.រ.ហ.អ ដទៃទៀតនោះទេ។

## ការបែកដាច់រវាងហានិភ័យធានារ៉ាប់រង និងហានិភ័យដទៃទៀត

B៨ និយមន័យនៃកិច្ចសន្យាធានារ៉ាប់រងមួយសំដៅដល់ហានិភ័យធានារ៉ាប់រង ដែល ស.រ.ហ.អ នេះ កំណត់ថាជាហានិភ័យ ក្រៅពី *ហានិភ័យហិរញ្ញវត្ថុ* ដែលបានផ្ទេរពីអ្នកកាន់កិច្ចសន្យាទៅអ្នកចេញកិច្ចសន្យា។ កិច្ចសន្យាមួយដែលបង្ហាញអ្នកចេញកិច្ចសន្យាឲ្យដឹងអំពីហានិភ័យហិរញ្ញវត្ថុ ហើយបើគ្មានហានិភ័យធានារ៉ាប់រងទេ វាមិនមែនជាកិច្ចសន្យាធានារ៉ាប់រងទេ។

B៩ និយមន័យនៃហានិភ័យហិរញ្ញវត្ថុនៅក្នុងឧបសម្ព័ន្ធ A រួមមានបញ្ជីនៃអថេរហិរញ្ញវត្ថុនិងមិនមែនហិរញ្ញវត្ថុ។ បញ្ជីនេះ រួមមានអថេរហិរញ្ញវត្ថុដែលមិន

មានភាពជាក់លាក់ចំពោះភាគីមួយនៃកិច្ចសន្យា ដូចជា សន្ទស្សន៍ការខាតបង់ពីការរញ្ជួយដីនៅក្នុងតំបន់ឬសន្ទស្សន៍នៃសីតុណ្ហភាពនៅក្នុងទីក្រុងមួយ។ វាដកចេញនូវអថេរមិនមែនហិរញ្ញវត្ថុ ដែលមានលក្ខណៈពិសេសចំពោះភាគីមួយនៃកិច្ចសន្យា ដូចជា ការកើតមាន ឬមិនកើតមាន នៃអគ្គីភ័យ ដែលធ្វើឱ្យខូចខាត ឬបំផ្លាញ នូវទ្រព្យសកម្មរបស់ភាគីនោះ។ ម្យ៉ាងវិញទៀត ហានិភ័យនៃការប្រែប្រួលតម្លៃទីផ្សាររបស់ទ្រព្យសកម្ម មិនមែនហិរញ្ញវត្ថុ មិនមែនជាហានិភ័យហិរញ្ញវត្ថុ ប្រសិនបើ តម្លៃទីផ្សារមិនគ្រាន់តែបង្ហាញអំពីការប្រែប្រួលថ្លៃទីផ្សារសម្រាប់ទ្រព្យសកម្មនេះ (អថេរហិរញ្ញវត្ថុ) ប៉ុន្តែថែមទាំងបង្ហាញឱ្យឃើញលក្ខខណ្ឌ នៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដោយឡែកដែលកាន់កាប់ដោយភាគីមួយ នៃកិច្ចសន្យា (អថេរមិនមែនហិរញ្ញវត្ថុ)។ ឧទាហរណ៍ ប្រសិនបើ ការធានាចំពោះតម្លៃដែលនៅសល់នៃរថយន្ត បង្ហាញដល់អ្នកធានារ៉ាប់រងចំពោះហានិភ័យនៃការប្រែប្រួលលើលក្ខខណ្ឌរូបរាងរបស់រថយន្ត ដែលនេះជាហានិភ័យធានារ៉ាប់រងមិនមែនជាហានិភ័យហិរញ្ញវត្ថុទេ។

B១០ កិច្ចសន្យាមួយចំនួនបង្ហាញដល់អ្នកចេញកិច្ចសន្យានូវហានិភ័យហិរញ្ញវត្ថុជាការបន្ថែម លើហានិភ័យធានារ៉ាប់រងចម្បង។ ឧទាហរណ៍ កិច្ចសន្យាធានារ៉ាប់រងជីវិតជាច្រើន ធានាទាំងអត្រាអប្បបរមានៃប្រាក់ចំណូល ចំពោះអ្នកកាន់សិទ្ធិធានារ៉ាប់រង (បង្កើតបាននូវហានិភ័យហិរញ្ញវត្ថុ) និងទាំងសន្យាអត្ថប្រយោជន៍ ពេលមរណៈភាព ដែលជួនកាលលើសសមតុល្យគណនេយ្យរបស់អ្នកកាន់សិទ្ធិធានារ៉ាប់រង (បង្កើតឡើងនូវហានិភ័យធានារ៉ាប់រងនៅក្នុងទម្រង់ជាហានិភ័យនៃមរណៈភាព)។ កិច្ចសន្យាបែបនេះ គឺជាកិច្ចសន្យាធានរ៉ាប់រង។

B១១ តាមកិច្ចសន្យាខ្លះ ព្រឹត្តិការណ៍ដែលបានធានា ធ្វើឲ្យមានការទូទាត់ចំនួនទឹកប្រាក់ដែលទាក់ទិនដល់សន្ទស្សន៍ថ្លៃ។កិច្ចសន្យាបែបនេះគឺជាកិច្ចសន្យាធានារ៉ាប់រង បានផ្តល់ការទូទាត់ ដែលមានភាពចៃដន្យ ដែលផ្អែកលើព្រឹត្តការណ៍ដែលបានធានាជាចម្បង។ ឧទាហរណ៍ ធនលាភជាយថាហេតុសម្រាប់ជីវិតដែលទាក់ទិននឹងសន្ទស្សន៍នៃតម្លៃសម្រាប់ការរស់នៅផ្ទាល់ នូវហានិភ័យធានារ៉ាប់រង ពីព្រោះថាការទូទាត់បានកើតមានឡើង ដោយសារតែព្រឹត្តិការណ៍មិនប្រាកដប្រជា ដែលជាសំណល់នៃធនលាភ ។ ទំនាក់ទំនងទៅនឹងសន្ទស្សន៍ថ្លៃគឺជានិស្សន្ទបង្កប់ ប៉ុន្តែវាក៏ផ្ទេរហានិភ័យធានារ៉ាប់រងដែរ ។ ប្រសិនបើការផ្ទេរហានិភ័យធានារ៉ាប់រងមានសារៈសំខាន់ចម្បង និស្សន្ទន៍បង្កប់បំពេញតាមអត្ថន័យនៃកិច្ចសន្យាធានរ៉ាប់រង ក្នុងករណីបែបនេះ វាចាំបាច់បំបែកវា និងមិនបាច់វាស់វែងតាមតម្លៃទីផ្សារទេ (សូមមើលកថាខ័ណ្ឌ ៧ នៃ ស.រ.ហ.អ នេះ)។

B១២ អត្ថន័យនៃ ហានិភ័យធានារ៉ាប់រង សំដៅដល់ហានិភ័យ ដែលអ្នកធានារ៉ាប់រងទទួលយកពីអ្នកកាន់សិទ្ធិធានារ៉ាប់រង។ និយាយម្យ៉ាងទៀតហានិភ័យធានារ៉ាប់រង គឺជាហានិភ័យដែលកើតមានមុនដែលបានផ្ទេរពីអ្នកកាន់សិទ្ធិធានារ៉ាប់រង ទៅអ្នកធានារ៉ាប់រង។ ដូចនេះ ហានិភ័យថ្មីដែលបង្កើត ដោយកិច្ចសន្យា មិនមែនជាហានិភ័យធានារ៉ាប់រងទេ។

B១៣ អត្ថន័យនៃកិច្ចសន្យាធានារ៉ាប់រង សំដៅដល់ឥទ្ធិពលបញ្ច្រាសលើអ្នកកាន់សិទ្ធិធានារ៉ាប់រង។ អត្ថន័យ មិនបានដាក់កំហិតចំពោះការទូទាត់ដោយអ្នកធានារ៉ាប់រងនូវទឹកប្រាក់ស្មើនឹងអានុភាពផ្នែកហិរញ្ញវត្ថុ នៃព្រឹត្តិការណ៍មិនអនុគ្រោះនោះទេ។ ឧទាហរណ៍ និយមន័យ មិនដកចេញនូវទំហំ "ថ្មីសម្រាប់ចាស់" ដែលទូទាត់ឲ្យអ្នកកាន់សិទ្ធិធានារ៉ាប់រងគ្រប់គ្រាន់ ដែល

អនុញ្ញាតឲ្យមានការជំនួសទ្រព្យសកម្មចាស់ដែលបានខូចខាត ដោយទ្រព្យសកម្មថ្មី។ ដូចគ្នានេះដែរ និយមន័យមិនកំណត់ព្រំដែនតាមកិច្ចសន្យាធានារ៉ាប់រងមានកំណត់ពេលចំពោះការខាតបង់ផ្នែកហិរញ្ញវត្ថុ ដែលបានទទួលរងដោយសារទាយាទរបស់អ្នកស្លាប់ និងមិនច្រានចោលការទូទាត់ចំនួនទឹកប្រាក់ ដែលបានកំណត់ទុកមុនសម្រាប់កំណត់ចំនួនការខាតបង់ដែលបណ្តាលមកពីមរណភាពឬគ្រោះថ្នាក់។

B១៤ កិច្ចសន្យាមួយចំនួន តម្រូវឲ្យមានការទូទាត់ ប្រសិនបើ ព្រឹត្តការណ៍មិនប្រាកដប្រជាដែលបានបញ្ជាក់កើតឡើង ប៉ុន្តែមិនតម្រូវឥទ្ធិពលត្រឡប់មកអ្នកកាន់សិទ្ធិធានារ៉ាប់រង ថាជាបុរេលក្ខខណ្ឌសម្រាប់ការទូទាត់។ កិច្ចសន្យាបែបនេះ មិនមែនជាកិច្ចសន្យាធានារ៉ាប់រងទេ ទោះបីជាអ្នកកាន់កិច្ចសន្យានោះប្រើនិស្សន្ទមួយដើម្បីការពារអថេរមិនមែនហិរញ្ញវត្ថុជាមូលដ្ឋាន ដែលទាក់ទងជាមួយលំហូរសាច់ប្រាក់ពីទ្រព្យសកម្មរបស់អង្គភាព នោះនិស្សន្ទមិនមែនជា កិច្ចសន្យាធានារ៉ាប់រងទេ ពីព្រោះថា ការទូទាត់មិនមែនជាលក្ខខណ្ឌ ថាតើអ្នកកាន់កិច្ចសន្យាទទួលឥទ្ធិពលបញ្ច្រាស ដោយសារតែការកាត់បន្ថយ នៅក្នុងលំហូរសាច់ប្រាក់ ពីទ្រព្យសកម្ម។ ផ្ទុយមកវិញអត្ថន័យនៃកិច្ចសន្យាធានារ៉ាប់រង សំដៅដល់ព្រឹត្តិការណ៍មិនប្រាកដប្រជាដែលឥទ្ធិពលបញ្ច្រាសលើអ្នកកាន់សិទ្ធិធានារ៉ាប់រង គឺជាលក្ខខណ្ឌកំណត់មុនតាមកិច្ចសន្យាសម្រាប់ការទូទាត់។ លក្ខខណ្ឌជាមុនតាមកិច្ចសន្យានេះមិនតម្រូវឲ្យអ្នកធានារ៉ាប់រងឲ្យស៊ើបអង្កេតថាតើព្រឹត្តិការណ៍ ដែលបណ្តាលឲ្យមានឥទ្ធិពលបញ្ច្រាសជាក់ស្តែងប៉ុន្តែអនុញ្ញាតឲ្យអ្នកធានារ៉ាប់រងបដិសេធមិនព្រមទូទាត់ ប្រសិនបើព្រឹត្តិការណ៍ដែលមានឥទ្ធិពលបញ្ច្រាសនោះមានលក្ខណៈសម្បត្តិមិនគ្រប់គ្រាន់។

B១៥ ការផុតរលត់ឬភាពយូរអង្វែងនៃហានិភ័យ (ដូចជា ហានិភ័យដែលភាគីម្ខាងទៀតបដិសេធកិច្ចសន្យាមុនឬក្រោយការកំណត់តម្លៃកិច្ចសន្យាដោយអ្នកចេញកិច្ចសន្យាបានរំពឹងទុក) មិនមែនជាហានិភ័យធានារ៉ាប់រងទេ ពីព្រោះថា ការទូទាត់ចំពោះភាគីម្ខាងទៀតមិនមែនកើតមានជាយថាហេតុសម្រាប់ព្រឹត្តការណ៍មិនប្រាកដប្រជានាពេលអនាគត ដែលមានឥទ្ធិពលបញ្ច្រាសមក ភាគីម្ខាងទៀតនោះទេ។ ស្រដៀងគ្នានេះដែរ ហានិភ័យចំណាយ (ដូចជា ហានិភ័យនៃកំណើនចំណាយរដ្ឋបាលដែលមិនបានគិតទុកមុនដែលមានជាប់ ជាមួយការផ្តល់សេវាកម្មតាមកិច្ចសន្យា វាលែងតែការកើនឡើងនៃចំណាយរដ្ឋបាលដែលជាប់ពាក់ព័ន្ធនឹងព្រឹត្តិការណ៍ ដែលបានធានា) មិនមែនជាហានិភ័យធានារ៉ាប់រងនោះទេ ពីព្រោះកំណើនចំណាយ ដែលមិនបានគិតទុកមុន មិនមានឥទ្ធិពលបញ្ច្រាសដល់ភាគីម្ខាងទៀតនោះទេ។

B១៦ ដូចនេះ កិច្ចសន្យាមួយដែលធ្វើឱ្យអ្នកធានារ៉ាប់រងទទួលហានិភ័យកន្លងហួសទៅ ទទួលរងហានិភ័យយូរអង្វែង ឬហានិភ័យចំណាយ មិនមែនជាហានិភ័យធានារ៉ាប់រងទេ វាលែងតែវាក៏ធ្វើឱ្យអ្នកធានារ៉ាប់រងទទួលរងហានិភ័យធានារ៉ាប់រង។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើអ្នកចេញកិច្ចសន្យា សម្រាលនូវហានិភ័យនោះដោយប្រើកិច្ចសន្យាទី២ដើម្បីផ្ទេរនូវហានិភ័យនោះដល់ភាគីដទៃទៀត កិច្ចសន្យាទី ២ ធ្វើឱ្យភាគីដទៃទៀត នោះរងនូវហានិភ័យធានារ៉ាប់រង។

B១៧ អ្នកធានារ៉ាប់រងអាចទទួលយកនូវហានិភ័យធានារ៉ាប់រងចម្បង ពីអ្នកកាន់សិទ្ធិធានារ៉ាប់រង តែប្រសិនបើអ្នកធានារ៉ាប់រង គឺជាអង្គភាពដែលខុស

ពីអ្នកកាន់សិទ្ធិធានារ៉ាប់រង។ ក្នុងករណីដែលវាជាអ្នកធានារ៉ាប់រងសង្គហៈ នោះសង្គហៈទទួលយកហានិភ័យពីអ្នកកាន់សិទ្ធិធានារ៉ាប់រង និងប្រមូលយកហានិភ័យនោះ។ ទោះបីជាអ្នកកាន់សិទ្ធិធានារ៉ាប់រងទ្រាំទ្រនូវហានិភ័យដែលបានទទួលជាសម្ធហភាពទៅតាមសមត្ថភាពក្នុងនាមជាម្ចាស់ សង្គហៈនៅតែទទួលយកហានិភ័យដែលជាសារជាតិនៃកិច្ចសន្យាធានារ៉ាប់រង។

## ឧទាហរណ៍នៃកិច្ចសន្យាធានារ៉ាប់រង

B១៨ ខាងក្រោម គឺជាឧទាហរណ៍នៃកិច្ចសន្យា ដែលជាកិច្ចសន្យាធានារ៉ាប់រង ប្រសិនបើការផ្ទេរហានិភ័យធានារ៉ាប់រង គឺមានសារៈសំខាន់÷

(ក) ធានារ៉ាប់រងចំពោះអំពើចោរកម្មឬការខូចខាតចំពោះទ្រព្យសម្បត្តិ។

(ខ) ធានារ៉ាប់រង ចំពោះបំណុលជាផលិតផល បំណុលវិជ្ជាជីវៈ បំណុលស៊ីវិល ឬចំណាយផ្នែកច្បាប់។

(គ) ធានារ៉ាប់រងជីវិត និងផែនការបញ្ចុះសព ដែលបានទូទាត់មុន (ទោះបីជាសេចក្តីវាប្រាកដជាមាន ប៉ុន្តែវាមិនប្រកដថាពេលណានឹងស្លាប់នោះទេ ឬសម្រាប់ប្រភេទកិច្ចសន្យាធានារ៉ាប់រងខ្លះថាតើសេចក្តីស្លាប់នឹងកើតមាននៅក្នុងការិយបរិច្ឆេទដែលគ្របដណ្តប់ដោយកិច្ចសន្យាដែរឬទេ)។

(ឃ) ធនលាភ សម្រាប់ជីវិតយថាហេតុ និងសោធននិវត្ត (ដូចជាកិច្ចសន្យាដែលផ្តល់ការទូទាត់ចំពោះព្រឹត្តិការណ៍មិនប្រាកដប្រជានាពេលអនាគត ការរស់រានមានជីវិតរបស់អ្នកទទួលធនលាភ ឬអ្នកទទួលសោធនិវត្ត ដើម្បីជួយដល់អ្នកទទួលធនលាភ ឬអ្នកទទួលសោធនិវត្តក្នុងការរក្សានូវកម្រិតជីវភាពរស់នៅ ដែលអាច

ទទួលឥទ្ធិពលបញ្ច្រាស ដោយសារការរស់រានមានជីវិតឡើងវិញរបស់អ្នកនោះ)។

(ង) ពិការភាពនិងការចំណាយលើថ្នាំពេទ្យ។

(ច) មូលបត្របំណុលមានការធានា សញ្ញាប័ណ្ណសុច្ចរិត និងសញ្ញាប័ណ្ណដេញថ្លៃ (កិច្ចសន្យាដែលផ្តល់ការទូទាត់ ប្រសិនបើភាគីដទៃទៀតខកខានមិនបានបំពេញកាតព្វកិច្ចតាមកិច្ចសន្យាឧទាហរណ៍ កិច្ចសន្យាសាងសង់អគារមួយ)។

(ឆ) ការធានាចំពោះឥណទាន សម្រាប់ការទូទាត់ជាក់លាក់ដែលត្រូវបានធ្វើឡើងសម្រាប់សងដល់អ្នកកាន់កិច្ចសន្យាចំពោះការខាតបង់ដែលកើតឡើងដោយសារតែម្ចាស់បំណុលខកខានមិនបានទូទាត់ពេលដល់កាលកំណត់សង តាមលក្ខខណ្ឌដើម ឬលក្ខខណ្ឌដែលបានកែប្រែនៃឧបករណ៍បំណុល។ កិច្ចសន្យាទាំងនេះ អាចមានទម្រង់ផ្នែកច្បាប់ផ្សេងគ្នាច្រើន ដូចជា ទម្រង់នៃការធានាប្រភេទមួយចំនួន នៃលិខិតឥណទាន និស្សន្ទឥណទានពីការខកខានអនុវត្តកិច្ចសន្យា ឬកិច្ចសន្យាធានារ៉ាប់រង។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ថ្វីបើកិច្ចសន្យាទាំងនេះបំពេញតាមនិយមន័យនៃកិច្ចសន្យាធានារ៉ាប់រង កិច្ចសន្យាទាំងនោះក៏បំពេញបានតាមនិយមន័យនៃកិច្ចសន្យាធានាហិរញ្ញវត្ថុនៅក្នុង ស.រ.ហ.អ លេខ ៩ និងក្រោមវិសាលភាពនៃស្តង់ដាគណនេយ្យអន្តរជាតិលេខ៣២* និង វិសាលភាព ស.រ.ហ.អ លេខ ៩ មិនមែនតាម ស.រ.ហ.អ នេះទេ (សូមមើលកថាខណ្ឌទី៤(ឃ)) ដែរ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើអ្នកធានារ៉ាប់រង នៃកិច្ចសន្យាធានារ៉ាប់រង

ហិរញ្ញវត្ថុ បានបញ្ជាក់អះអាងពីមុនមកថា ខ្លួនចាត់ទុកកិច្ចសន្យាបែបនេះថាជាកិច្ចសន្យាធានារ៉ាប់រង ហើយបានប្រើប្រាស់កំណត់ត្រាគណនេយ្យដែលអាចអនុវត្តបានចំពោះកិច្ចសន្យាធានារ៉ាប់រង អ្នកចេញធានារ៉ាប់រង អាចជ្រើសយកមកអនុវត្តនូវស្តង់ដាគណនេយ្យអន្តរជាតិលេខ ៣២† និងស.រ.ហ.អ លេខ ៩ ឬស.រ.ហ.អ នេះ ចំពោះកិច្ចសន្យាធានារ៉ាប់រងហិរញ្ញវត្ថុបែបនេះ។

(ជ) ការធានាចំពោះផលិតផល។ ការធានាចំពោះផលិតផល ដែលចេញដោយភាគីដទៃទៀតសម្រាប់ទំនិញដែលបានលក់រួច ដោយផលិតករ អ្នកលក់ដុំ ឬអ្នកលក់រាយ គឺស្ថិតក្រោមវិសាលភាព នៃស្តង់ដានេះ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏ការធានាលើផលិតផលដែលចេញដោយផ្ទាល់ដោយអ្នកផលិត អ្នកលក់ដុំ ឬអ្នកលក់រាយ ស្ថិតក្រៅវិសាលភាពនៃស្តង់ដានេះ ពីព្រោះថាការធានាទាំងនោះ ស្ថិតក្នុងវិសាលភាព នៃស្តង់ដាគណនេយ្យអន្តរជាតិលេខ ១៨ និង ៣៧។

(ឈ) ការធានារ៉ាប់រងលើកម្មសិទ្ធិ (ដូចជា ធានារ៉ាប់រងលើរបកគំហើញនៃការបាត់បង់កម្មសិទ្ធិដី ដែលមិនបានកើតឡើងនៅពេលធ្វើកិច្ចសន្យាធានារ៉ាប់រង)។ ក្នុងករណីនេះ ព្រឹត្តិការណ៍ដែលបានធានាគឺជារបកគំហើញនៃការបាត់បង់លើកម្មសិទ្ធិ មិនមែនលើការបាត់បង់នោះទេ។

(ញ) ជំនួយការធ្វើដំណើរ (ដូចជា ការទូទាត់ជាសាច់ប្រាក់ ឬជាវត្ថុដល់អ្នកកាន់សិទ្ធិធានារ៉ាប់រង សម្រាប់រាល់ការបាត់បង់ ដែល

ទទួលរងនៅពេលដែលគេកំពុងធ្វើដំណើរ)។ កថាខ័ណ្ឌ B៦ និង B៧ ពិភាក្សាអំពីកិច្ចសន្យាប្រភេទនេះមួយចំនួន។

(ជ) សញ្ញាប័ណ្ណគ្រោះមហន្តរាយ ដែលបានផ្តល់ឲ្យ សម្រាប់ទូទាត់ដែលបានកាត់បន្ថយចំពោះប្រាក់ដើម ការប្រាក់ ឬទាំងពីរ ប្រសិនបើព្រឹត្តិការណ៍ជាក់លាក់មួយមានឥទ្ធិពលបញ្ច្រាសដល់អ្នកចេញប័ណ្ណ (វាលែងតែ ព្រឹត្តិការណ៍ជាក់លាក់ មិនបង្កើតបាននូវហានិភ័យធានារ៉ាប់រងចម្បង ឧទាហរណ៍ ប្រសិនបើព្រឹត្តិការណ៍គឺជាការកែប្រែអត្រាការប្រាក់ ឬអត្រាប្តូររូបិយប័ណ្ណបរទេស)។

(ឈ) ការដូរមានធានារ៉ាប់រង និងកិច្ចសន្យាដទៃទៀតដែលតម្រូវឲ្យមានការទូទាត់ដោយផ្អែកលើការប្រែប្រួលអាកាសធាតុ ភូមិសាស្ត្រ ឬអថេររូបវន្តដទៃទៀត ដែលមានលក្ខណៈដោយឡែក សម្រាប់ភាគីមួយនៃកិច្ចសន្យា។

(ញ) កិច្ចសន្យាធានារ៉ាប់រងបន្ត។

B១៩ ខាងក្រោម គឺជាឧទាហរណ៍អំពីធាតុនានាដែលមិនមែនជាកិច្ចសន្យាធានារ៉ាប់រង÷

(ក) កិច្ចសន្យាវិនិយោគ ដែលមានទម្រង់ខាងផ្លូវច្បាប់ នៃកិច្ចសន្យាធានារ៉ាប់រង ប៉ុន្តែមិនផ្តល់ដល់អ្នកធានារ៉ាប់រងនូវហានិភ័យធានារ៉ាប់រងនោះទេ ឧទាហរណ៍ កិច្ចសន្យាធានារ៉ាប់រងជីវិតដែលក្នុងនោះអ្នកធានារ៉ាប់រង មិនទទួលរងនូវហានិភ័យ នៃមរណភាពអ្វីចម្បងនោះទេ (ដូចជា កិច្ចសន្យានានាដែលមិនមែនជាឧបករណ៍ហិរញ្ញវត្ថុដែលត្រូវធានារ៉ាប់រង ឬកិច្ចសន្យាសេវាកម្ម សូមមើលកថាខ័ណ្ឌ B២០ និង B២១)។

(ខ) កិច្ចសន្យាដែលមានទម្រង់ខាងផ្លូវច្បាប់នៃកិច្ចសន្យាធានារ៉ាប់រង ប៉ុន្តែបានឆ្លងផុតរាល់ហានិភ័យធានារ៉ាប់រងចម្បងទាំងអស់ ចំពោះអ្នកកាន់សិទ្ធិធានារ៉ាប់រង តាមរយៈយន្តការដែលមិនអាចបដិសេធបាន និងអាចអនុវត្តបាន ដែលធ្វើការកែតម្រូវលើការទូទាត់ នាពេលអនាគតដោយអ្នកកាន់សិទ្ធិធានារ៉ាប់រងថាជាលទ្ធផលដោយផ្ទាល់នៃការខាតបង់ដែលបានធានា ឧទាហរណ៍ កិច្ចសន្យាធានារ៉ាប់រងហិរញ្ញវត្ថុមួយចំនួន ឬក្រុមនៃកិច្ចសន្យាធានារ៉ាប់រងមួយចំនួន (ជាធម្មតា កិច្ចសន្យាទាំងនោះ គឺជាកិច្ចសន្យាសម្រាប់ឧបករណ៍ហិរញ្ញវត្ថុមិនធានារ៉ាប់រងឬកិច្ចសន្យាសេវាកម្មសូមមើលកថាខ័ណ្ឌ B២០ និង B២១)។

(គ) ការធានារ៉ាប់រងដោយខ្លួនឯង ឬនិយាយម្យ៉ាងទៀត ការរក្សាទុកហានិភ័យមួយ ដែលអាចគ្របដណ្តប់ដោយការធានារ៉ាប់រង (មិនមានកិច្ចសន្យាធានារ៉ាប់រងទេ ពីព្រោះពុំមានការព្រមព្រៀងជាមួយភាគីមួយទៀត)។

(ឃ) កិច្ចសន្យា (ដូចជា កិច្ចសន្យាល្បែងស៊ីសង) ដែលតម្រូវឱ្យមានការទូទាត់ ប្រសិនបើព្រឹត្តិការណ៍ មិនប្រាកដប្រជាជាក់លាក់នាពេលអនាគតកើតមានឡើង ដែលជាលក្ខខណ្ឌកំណត់មុន តាមកិច្ចសន្យា ឲ្យមានការទូទាត់ ប៉ុន្តែមិនតម្រូវថាព្រឹត្តិការណ៍មានឥទ្ធិពលបញ្ច្រាសដល់អ្នកកាន់សិទ្ធិធានារ៉ាប់រងនោះទេ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ការណ៍នេះមិនច្រានចោលនូវការបញ្ជាក់អំពីចំនួនទឹកប្រាក់ដែលបានកំណត់មុន ដើម្បីកំណត់បរិមាណនៃ

ការខាតបង់ ដែលបណ្ដាលមកពីព្រឹត្តិការណ៍ជាក់លាក់ ដូចជា មរណៈភាព ឬគ្រោះថ្នាក់( សូមមើលផងដែរនូវកថាខ័ណ្ឌ B១៣)។

(ង) និស្សន្ទដែលនាំឱ្យភាគីមួយទទួលរងហានិភ័យហិរញ្ញវត្ថុ ប៉ុន្តែមិនមែនជា ហានិភ័យធានារ៉ាប់រងនោះទេ ពីព្រោះនិស្សន្ទទាំងនោះតម្រូវឱ្យភាគីនោះធ្វើការទូទាត់ដោយផ្អែកលើតែការប្រែប្រួលលើអត្រាការប្រាក់ជាក់លាក់មួយ ឬច្រើន លើថ្លៃឧបករណ៍ហិរញ្ញវត្ថុ ថ្លៃទំនិញ អត្រាប្តូររូបិយប័ណ្ណបរទេស សន្ទស្សន៍ថ្លៃ អត្រាឥណទានឬសន្ទស្សន៍ឥណទាន ឬអថេរដទៃទៀត ដែលការប្រែប្រួលនោះ បានផ្ដល់ចំពោះករណីអថេរមិនមែនហិរញ្ញវត្ថុ ដែលអថេរមិនមានភាពជាក់លាក់ចំពោះភាគីនៃកិច្ចសន្យា (សូមមើល ស.រ.ហ.អ លេខ៩)។

(ច) ការធានាទាក់ទងនឹង ឥណទាន (ឬលិខិតឥណទាន និស្សន្ទឥណទានពីការខកខានអនុវត្តកិច្ចសន្យា ឬកិច្ចសន្យាធានារ៉ាប់រងឥណទាន) ដែលតម្រូវឱ្យទូទាត់ ទោះបីជាអ្នកកាន់កិច្ចសន្យាមិនទទួលរងការខាតបង់ពីការខកខានរបស់កូនបំណុលក្នុងការទូទាត់ពេលដល់កាលកំណត់សងក៏ដោយ (សូមមើល ស.រ.ហ.អ លេខ ៩)។

(ឆ) កិច្ចសន្យា ដែលតម្រូវឱ្យមានការទូទាត់ ដោយផ្អែកលើអថេរអាកាសធាតុ ភូមិសាស្ត្រ ឬអថេររូបវន្តដទៃទៀត ដែលមិនមានភាពជាក់លាក់ចំពោះភាគីមួយនៃកិច្ចសន្យា (ជារួម មានពិពណ៌នាថាជានិស្សន្ទអាកាសធាតុ)។

(ជ) សញ្ញាប័ណ្ណគ្រោះមហន្តរាយ ដែលបានផ្តល់ឱ្យ សម្រាប់ទូទាត់ដែលបានកាត់បន្ថយចំពោះប្រាក់ដើម ការប្រាក់ ឬទាំងពីរ ដោយផ្អែកលើអថេរអាកាសធាតុ ភូមិសាស្ត្រ ឬអថេររូបវន្តដទៃទៀត ដែលមិនមានភាពជាក់លាក់ចំពោះភាគីនៃកិច្ចសន្យាណាមួយ។

B២០ ប្រសិនបើកិច្ចសន្យាដែលបានពិពណ៌នានៅក្នុងកថាខ័ណ្ឌ B១៩ បង្កើតបានជាទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ កិច្ចសន្យាទាំងនោះស្ថិតនៅក្នុងវិសាលភាពនៃ ស.រ.ហ.អ លេខ ៩។ ក្នុងចំណោមវត្ថុធាតុដទៃទៀតនេះមានន័យថាភាគីនានានៃកិច្ចសន្យា ប្រទូវអ្វីដែលជួនកាលហៅថា ការកត់ត្រាគណនេយ្យ ចំពោះប្រាក់បញ្ញើ ដែលបាក់ព័ន្ធទៅនឹងចំណុចខាងក្រោម÷

(ក) ភាគីមួយទទួលស្គាល់តម្លៃតបស្នងដែលបានទទួល ថាជាបំណុលហិរញ្ញវត្ថុ ជាជាងថាជាចំណូល។

(ខ) ភាគីដទៃទៀតទទួលស្គាល់តម្លៃតបស្នងដែលបានបង់សង ថាជាទ្រព្យសកម្មហិរញ្ញវត្ថុ ជាជាងថាជាចំណាយ។

B២១ ប្រសិនបើកិច្ចសន្យាដែលបានពិពណ៌នានៅក្នុងកថាខ័ណ្ឌ B១៩ មិនបង្កើតបានជាទ្រព្យសកម្ម ឬបំណុលហិរញ្ញវត្ថុ នោះគេត្រូវអនុវត្តស្តង់ដាគណនេយ្យ អន្តរជាតិលេខ ១៨។ តាមស្តង់ដាគណនេយ្យអន្តរជាតិលេខ ១៨ ចំណូល ដែលមានជាប់ជាមួយ ប្រតិបត្តិការមួយ ពាក់ព័ន្ធនឹងការផ្តល់សេវាកម្ម ត្រូវបានទទួលស្គាល់ដោយយោងលើដំណាក់កាលនៃការបំពេញប្រតិបត្តិការ ប្រសិនបើទិន្នផលនៃប្រតិបត្តិការ អាចត្រូវបានប៉ាន់ស្មានគួរឱ្យទុកចិត្ត។

**ហានិភ័យធានារ៉ាប់រងចម្បង**

B២២ កិច្ចសន្យាមួយ ជាកិច្ចសន្យាធានារ៉ាប់រង តែនៅពេលដែលកិច្ចសន្យានោះផ្ទេរនូវហានិភ័យធានារ៉ាប់រងចម្បង។ កថាខ័ណ្ឌ B៨ - B២១ ពិភាក្សាអំពីហានិភ័យធានារ៉ាប់រង។ កថាខ័ណ្ឌខាងក្រោម ពិភាក្សាអំពីការវាយតម្លៃថាតើហានិភ័យធានារ៉ាប់រងមានលក្ខណៈចម្បងយ៉ាងណា។

B២៣ ហានិភ័យធានារ៉ាប់រងមានលក្ខណៈចម្បង ប្រសិនបើឬទាល់តែព្រឹត្តិការណ៍ដែលបានធានា អាចនាំឱ្យអ្នកធានារ៉ាប់រង ទូទាត់អត្ថប្រយោជន៍ចម្បងបន្ថែមតាមវិធីណាមួយ ដោយមិនរាប់បញ្ចូលវិធី ដែលខ្វះសារជាតិជាពាណិជ្ជកម្ម (ដូចជា មិនមានឥទ្ធិពលលើផ្នែកសេដ្ឋកិច្ចនៃប្រតិបត្តិការ)។ ប្រសិនបើអត្ថប្រយោជន៍ចម្បងបន្ថែម អាចត្រូវបានទូទាត់តាមវិធីដែលមានសារជាតិជាពាណិជ្ជកម្ម លក្ខខណ្ឌនៅក្នុងប្រយោគមុនៗ អាចត្រូវបានបំពេញ ទោះបីជាព្រឹត្តិការណ៍ដែលបានធានាពិតជាមិនកើតមាន ឬទោះបីជាតម្លៃជាក់ស្តែងដែលរំពឹងទុក (ដូចជា អាចថ្លឹងថ្លែងបាន) នៃលំហូរសាច់ប្រាក់យថាហេតុ ជាចំណែកមួយតូចនៃតម្លៃជាក់ស្តែង ដែលបានរំពឹងទុកនៃលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលនៅសល់ទាំងអស់។

B២៤ អត្ថប្រយោជន៍បន្ថែមដែលពិពណ៌នានៅក្នុងកថាខ័ណ្ឌ B២៣ សំដៅដល់ចំនួនទឹកប្រាក់ ដែលលើសពីចំនួនដែលអាចទូទាត់ ប្រសិនបើគ្មានព្រឹត្តិ-ការណ៍ដែលបានធានាកើតឡើង (មិនគិតចូលនូវវិធីដែលខ្វះសារជាតិជាពាណិជ្ជកម្ម)។ ចំនួនទឹកប្រាក់បន្ថែមទាំងនោះ រាប់បញ្ចូលការដោះស្រាយចំពោះការទាមទារ និងថ្លៃដើមវាយតម្លៃការទាមទារ ប៉ុន្តែមិនរាប់បញ្ចូលនូវ÷

(ក) ការបាត់បង់លទ្ធភាព ទាមទារប្រាក់ពី អ្នកកាន់សិទ្ធិធានារ៉ាប់រង សម្រាប់សេវាកម្មនាពេលអនាគត។ ឧទាហរណ៍ នៅក្នុងកិច្ចសន្យាធានារ៉ាប់រងជីវិតពាក់ព័ន្ធនឹងការវិនិយោគ មរណៈភាពរបស់អ្នកកាន់សិទ្ធិធានារ៉ាប់រង មានន័យថាអ្នកធានារ៉ាប់រង មិនអាចផ្តល់សេវាកម្មគ្រប់គ្រងវិនិយោគទៀតទេ ហើយអ្នកនោះ ប្រមូលប្រាក់កម្រៃដើម្បីធ្វើកិច្ចការនេះ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ការខាតបង់ខាងសេដ្ឋកិច្ចសម្រាប់អ្នកធានារ៉ាប់រងនេះ មិនបង្ហាញអំពីហានិភ័យធានារ៉ាប់រង ហើយវាគ្រាន់តែមានន័យថា អ្នកគ្រប់គ្រងមូលនិធិសង្គហៈ មិនទទួលយកហានិភ័យធានារ៉ាប់រង ទាក់ទិនទៅនឹង មរណៈភាព ដែលអាចកើតមាន របស់អតិថិជន។ ដូចនេះ ការខាតបង់សក្តានុពលនៃថ្លៃឈ្នួល សម្រាប់គ្រប់គ្រងវិនិយោគនាពេលអនាគត មិនពាក់ព័ន្ធនឹងការវាយតម្លៃ ថាតើហានិភ័យធានារ៉ាប់រងត្រូវបានផ្ទេរដោយកិច្ចសន្យាយ៉ាងដូចម្តេច ឬយ៉ាងណានោះទេ។

(ខ) សំបុត្របដិសេធការទាមទារប្រាក់នៃមរណៈភាព អាចត្រូវបានធ្វើឡើងតាមការលុបចោល ឬច្រានចោល។ ដោយសារតែកិច្ចសន្យាធ្វើឲ្យការទាមទារប្រាក់នោះកើតមានឡើង សំបុត្របដិសេធនៃការទាមទារនេះ មិនទូទាត់ដល់អ្នកកាន់សិទ្ធិធានារ៉ាប់រងចំពោះហានិភ័យដែលមានមុននោះទេ។ ដូចនេះ វាមិនពាក់ព័ន្ធនឹងការវាយតម្លៃថាតើ ហានិភ័យធានារ៉ាប់រង ត្រូវបានផ្ទេរដោយកិច្ចសន្យាយ៉ាងដូចម្តេច ចំនួនប៉ុន្មាននោះទេ។

(គ) ការទូទាត់ ដែលអាស្រ័យលើលក្ខខណ្ឌ នៃព្រឹត្តិការណ៍ដែលមិនបណ្ដាលឱ្យមានការខាតបង់ជាចម្បង ចំពោះអ្នកកាន់កិច្ចសន្យានោះទេ។ ឧទាហរណ៍ សូមពិចារណាលើកិច្ចសន្យាមួយ ដែលតម្រូវឱ្យអ្នកចេញកិច្ចសន្យាទូទាត់ ១ លាននៃឯកតារូបិយប័ណ្ណ ប្រសិនបើទ្រព្យសកម្មមួយទទួលរងនូវការខូចខាតជារូបវន្តដែលបណ្ដាលមកពីការខាតបង់ ផ្នែកសេដ្ឋកិច្ចមិនចម្បង នៃឯកតារូបិយប័ណ្ណចំពោះអ្នកកាន់កិច្ចសន្យា។ ក្នុងកិច្ចសន្យានេះ អ្នកកាន់កិច្ចសន្យាផ្ទេរទៅអ្នកធានារ៉ាប់រង នូវហានិភ័យមិនចម្បង ដែលបណ្ដាលមកពីការខាតបង់ឯកតារូបិយប័ណ្ណ។ ក្នុងពេលជាមួយគ្នានេះដែរ កិច្ចសន្យាបង្កើតនូវហានិភ័យមិនមែនធានារ៉ាប់រងដែលអ្នកចេញកិច្ចសន្យាចាំបាច់ត្រូវទូទាត់ ៩៩៩,៩៩៩ ឯកតា រូបិយ-ប័ណ្ណបើព្រឹត្តការណ៍ជាក់លាក់បានកើតឡើង។ ដោយសារតែ អ្នកចេញធានារ៉ាប់រង មិនទទួលយកហានិភ័យធានារ៉ាប់រងចម្បង ពីអ្នកកាន់កិច្ចសន្យា កិច្ចសន្យានេះមិនមែនជាកិច្ចសន្យាធានារ៉ាប់រងនោះទេ។

(ឃ) លទ្ធភាពទទួលបានមកវិញ នូវការធានារ៉ាប់រងបន្ត។ អ្នកធានារ៉ាប់រងត្រូវកត់ត្រាគណនេយ្យដាច់ដោយឡែកពីគ្នា។

B២៥ អ្នកធានារ៉ាប់រងត្រូវវាយតម្លៃភាពចម្បង នៃហានិភ័យធានារ៉ាប់រង តាមកិច្ចសន្យាមួយៗ ជាជាងដោយយោងលើ ភាពសារវន្ត នៃរបាយការណ៍ហិរញ្ញវត្ថុ។ *ដូច្នេះ ហានិភ័យធានារ៉ាប់រងអាចមានភាពចម្បង ទោះបីជាមានការជឿជាក់តិចតួចថាវានាំឱ្យមានការខាតបង់ជាសារវន្តសម្រាប់បណ្ដុំកិច្ចសន្យាទាំងមូលក៏ដោយ។ ការវាយតម្លៃទៅតាមកិច្ចសន្យាដូចនេះ ធ្វើឱ្យ

មានភាពងាយស្រួលក្នុងការចាត់ថ្នាក់កិច្ចសន្យាមួយ ថាជាកិច្ចសន្យាធានារ៉ាប់រង ឬយ៉ាងណា។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើបណ្តុំនៃកិច្ចសន្យាតូច បង្កើតបានជាកិច្ចសន្យាដែលផ្ទេរហានិភ័យធានារ៉ាប់រងទាំងអស់ អ្នកធានារ៉ាប់រងមិនចាំបាច់ត្រួតពិនិត្យកិច្ចសន្យាមួយៗ នៅក្នុងបណ្តុំកិច្ចសន្យាដើម្បីបញ្ជាក់អំពីកិច្ចសន្យាមិនមែននិស្សន្ទមួយចំនួន ដែលផ្ទេរនូវហានិភ័យធានារ៉ាប់រងមិនចម្បងនោះទេ។

B២៦ វាបន្តពីកថាខ័ណ្ឌ B២៣-B២៥ ដែលថា ប្រសិនបើកិច្ចសន្យាមួយទូទាត់ចំពោះអត្ថប្រយោជន៍បានពីមរណៈភាពលើសពីចំនួនទឹកប្រាក់ ដែលអាចទូទាត់ពេលមានជីវិតរស់នៅ កិច្ចសន្យា គឺជាកិច្ចសន្យាធានារ៉ាប់រង វាលែងតែអត្ថប្រយោជន៍នៃមរណៈភាពបន្ថែម មិនសំខាន់ (សម្រេចដោយយោងលើកិច្ចសន្យា ជាជាងលើបណ្តុំនៃកិច្ចសន្យាទាំងមូល)។ ដូចដែលបានកត់សំគាល់នៅក្នុងកថាខ័ណ្ឌ B២៤(ខ) សំបុត្របដិសេធមរណៈភាព ឬលុបចោលបន្ទុកចំណាយ មិនត្រូវបានបញ្ចូលនៅក្នុងការវាយតម្លៃនេះទេ ប្រសិនបើសំបុត្របដិសេធនេះ មិនទូទាត់ដល់ អ្នកកាន់សិទ្ធិធានារ៉ាប់រងសម្រាប់ហានិភ័យដែលកើតមានមុន។ ដូចគ្នានេះដែរ កិច្ចសន្យាបុព្វលាភដែលត្រូវទូទាត់សងជាចំនួនទឹកប្រាក់ទៀតទាត់ សម្រាប់រយៈពេលនៃជីវិតដែលនៅសល់របស់អ្នកកាន់សិទ្ធិធានារ៉ាប់រង គឺជាកិច្ចសន្យាធានារ៉ាប់រង វាលែងតែការទូទាត់សរុបសម្រាប់ជីវិតជាយថាហេតុមិនមានសារៈសំខាន់។

B២៧ កថាខ័ណ្ឌ B២៣ សំដៅដល់អត្ថប្រយោជន៍បន្ថែម។ អត្ថប្រយោជន៍បន្ថែមនេះ អាចបញ្ចូលនូវការតម្រូវឱ្យទូទាត់នូវ អត្ថប្រយោជន៍ជាមុន ប្រសិនបើព្រឹត្តិការណ៍ដែលបានធានាកើតឡើងមុន ហើយការទូទាត់មិនត្រូវបានកែតម្រូវតាមតម្លៃពេលវេលានៃលុយ។ ឧទាហរណ៍ គឺការធានា

រ៉ាប់រងមួយជីវិត សម្រាប់ចំនួនទឹកប្រាក់ជាកំណត់មួយ (និយាយម្យ៉ាងទៀត ធានារ៉ាប់រងដែលផ្តល់អត្ថប្រយោជន៍ចំពោះមរណៈភាពមានកំណត់ នៅពេលណាក៏ដោយដែលអ្នកកាន់សិទ្ធិធានារ៉ាប់រងបានស្លាប់ ដោយពុំមានផុតកាលបរិច្ឆេទគ្របដណ្តប់ទេ)។ វាប្រាកដណាស់ហើយថា អ្នកកាន់សិទ្ធិធានារ៉ាប់រងនឹងស្លាប់ ប៉ុន្តែកាលបរិច្ឆេទស្លាប់មានភាពមិនប្រាកដប្រជា។ អ្នកធានារ៉ាប់រង នឹងទទួលរងការខាតបង់លើ កិច្ចសន្យាមួយៗទាំងនោះ ដែលអ្នកកាន់សិទ្ធិធានារ៉ាប់រងបានស្លាប់មុន ទោះបីជាពុំមានការខាតបង់ជាទូទៅលើបណ្តុំនៃកិច្ចសន្យាក៏ដោយ។

B២៨ ប្រសិនបើ កិច្ចសន្យាធានារ៉ាប់រងមិនបានចងក្រង ជាសមាសធាតុប្រាក់ដំកល់ និងជាសមាសធាតុធានារ៉ាប់រងទេ សារៈសំខាន់នៃការផ្ទេរហានិភ័យធានារ៉ាប់រង ត្រូវបានវាយតម្លៃដោយសំអាងលើសមាសធាតុធានារ៉ាប់រង។ សារៈសំខាន់នៃហានិភ័យធានារ៉ាប់រងដែលបានផ្ទេរដោយនិស្សន្ទបង្កប់ ត្រូវបានវាយតម្លៃដោយយោងលើនិស្សន្ទបង្កប់។

## ការប្រែប្រួលលើកម្រិតនៃហានិភ័យធានារ៉ាប់រង

B២៩ កិច្ចសន្យាខ្លះមិនផ្ទេរហានិភ័យធានារ៉ាប់រងណាមួយដល់អ្នកចេញកិច្ចសន្យានាពេលចាប់ផ្តើមនោះទេ ដូចនេះ កិច្ចសន្យាទាំងនោះផ្ទេរហានិភ័យធានារ៉ាប់រងនាពេលក្រោយមក។ ឧទាហរណ៍ ចូរពិចារណាលើកិច្ចសន្យាមួយដែលផ្តល់នូវចំណូលពីវិនិយោគជាក់លាក់ និងដែលបញ្ចូលជម្រើសមួយសម្រាប់អ្នកកាន់សិទ្ធិធានារ៉ាប់រងក្នុងការប្រើប្រាស់ចំណូលវិនិយោគនៅពេលដល់កាលកំណត់ដើម្បីទិញធនលាភ សម្រាប់ជីវិតជាយថាហេតុតាមអត្រាថ្លៃធនលាភជាក់ស្តែងដែលយកដោយអ្នកធានារ៉ាប់រង ចំពោះអ្នក

ទទួលផលលាភថ្មីដទៃទៀត នៅពេលដែលអ្នកកាន់សិទ្ធិធានារ៉ាប់រងអនុវត្តនូវជម្រើស។ កិច្ចសន្យាមិនផ្ទេរនូវហានិភ័យធានារ៉ាប់រងណាមួយ ចំពោះអ្នកចេញកិច្ចសន្យាទេ រហូតដល់ជម្រើសត្រូវបានធ្វើឡើង ពីព្រោះថាអ្នកធានារ៉ាប់រងនៅតែមានសេរីភាពក្នុងការកំណត់ថ្លៃ សម្រាប់ផលលាភ ដោយឈរលើមូលដ្ឋានមួយដែលបង្ហាញឱ្យឃើញនូវហានិភ័យធានារ៉ាប់រង ដែលបានផ្ទេរដល់អ្នកធានារ៉ាប់រងនាពេលនោះ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើអ្នកធានារ៉ាប់រងកំណត់ច្បាស់នូវអត្រាថ្លៃផលលាភ (ឬមូលដ្ឋានសម្រាប់កំណត់ថ្លៃផលលាភ) កិច្ចសន្យា ផ្ទេរនូវហានិភ័យធានារ៉ាប់រងដល់អ្នកចេញកិច្ចសន្យាតាំងពីពេលចាប់ផ្តើមកិច្ចសន្យា។

B៣០ កិច្ចសន្យាមួយដែលមានលក្ខណៈសម្បត្តិជាកិច្ចសន្យាធានារ៉ាប់រង មានការសន្យាធានារ៉ាប់រងរហូតដល់សិទ្ធិនិងកាតព្វកិច្ចទាំងអស់ត្រូវបានរលត់ ឬហួសពេល។

ក្រុមប្រឹក្សាជាតិគណនេយ្យ
ក.ជ.គ គឺជាស្ថាប័នបញ្ញត្តិករនៃវិស័យគណនេយ្យ និងសវនកម្មនៅកម្ពុជា
អាស័យដ្ឋាន៖ ផ្លូវ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
អ៊ីម៉ែល៖ info@naccambodia.gov.kh | គេហទំព័រ៖ www.naccambodia.gov.kh

ក.ជ.គ រក្សាសិទ្ធិក្នុងការកែប្រែស្លង់ដាទៅតាមការវិវត្តក្នុងក្របខណ្ឌអន្តរជាតិ